FIRST FINANCE

# ដៃគូដំណោះស្រាយ ហិរញ្ញវត្ថុផ្នែក លំនៅដ្ឋាន

របាយការណ៍ប្រចាំឆ្នាំ ២០២១



# មាតិកា

០៤. សាររួមពី អគ្គនាយិកា និង ប្រធានក្រុមប្រឹក្សាភិបាល
០៦. អំពី ហ្វឹស ហ្វាយនែន
០៨. សមិទ្ធផលរបស់យើង
១០. អំពីផលិតផល
១១. តំបន់ប្រតិបត្តិការ
១២. ហ្វឹស ហ្វាយនែន ទទួលបានវិញ្ញាបនបត្រ
១៣. ទិដ្ឋភាពទូទៅនៃអាជីវកម្ម
១៥ ការឆ្លើយតបនឹងកូវីដ
១៦. ដៃគូវិនិយោគរបស់យើង
១៧. រចនាសម្ព័ន្ធ ហ្វឹស ហ្វាយនែន
១៨. រឿងរបស់អតិថិជន
២០. របាយការណ៍របស់សវនករឯករាជ្យ
២២. របាយការណ៍ហិរញ្ញវត្ថុ
២៦. រឿងរបស់អតិថិជន
២៨. ក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំ

*តួលេខក្នុងរបាយការណ៍នេះ គឺរបស់ ហ្វឹស ហ្វាយនែន សម្រាប់ការិយបរិច្ឆេទ ០១ មករា ២០២១ ដល់ ៣១ ធ្នូ ២០២១*



Hanco Halbertsma
ប្រធានក្រុមប្រឹក្សាភិបាល

# សាររួមពីអគ្គនាយិកា និង ប្រធានក្រុមប្រឹក្សាភិបាល

ឥទ្ធិពលដែលបណ្តាលមកពីការរាលដាលរបស់ជម្ងឺកូវីដ ១៩ នៅក្នុងឆ្នាំ ២០២០ បានចាប់ផ្តើមថមថយនៅដើមឆ្នាំ ២០២១ តែការរាលដាលនោះ បានកំរើកមកវិញពេញទំហឹង នៅក្នុងកំឡុងត្រីមាសទី២ និងទី៣ ជាហេតុធ្វើអោយមានការបិទខ្ទប់នៅតំបន់ខ្លះដែលមានផ្ទុកមេរោគ និងមានការរឹតបន្តឹងលើការធ្វើដំណើរ ។ កត្តានេះបានធ្វើអោយឆ្នាំ ២០២១ នៅតែជាឆ្នាំប្រឈមមួយ ដែលផ្តល់នូវទុក្ខលំបាកទៅដល់ បុគ្គលិក អតិថិជន និងអ្នកដែលពាក់ពន្ធ័ជាមួយ ហ្វឹស ហ្វាយនែន ជាច្រើននាក់ទៀត ។ វិបត្តិនេះបានធ្វើអោយមានការប៉ះពាល់ដល់អាជីវកម្មខ្នាតតូចជាច្រើន ដែលក្នុងកំឡុងពេលនោះដែរ ហ្វឹស ហ្វាយនែន បានចូលរួមចំណែកជួយដល់អតិថិជនរបស់ខ្លួនប្រមាណ ២៥០ គ្រួសារ ប្រហែលជា ១៤% នៃអតិថិជនសរុប ដោយបានរៀបចំកម្ចីឡើងវិញ ដើម្បីសម្រួលជាបណ្តោះអាសន្នដល់ការបង់សង ក្នុងកំឡុងពេលដែលចំណូលមានការថយចុះ ។ គណៈគ្រប់គ្រងនៅការិយាល័យកណ្តាល និងបុគ្គលិកទាំងអស់នៅតាមសាខាបាន និងនៅតែបន្តផ្តល់ការគាំទ្រដល់អតិថិជន ក្រុមគ្រួសារ និងអាជីវកម្មរបស់ពួកគេដែលទទួលរងផលប៉ះពាល់ដោយកូវីដ ។

ស្ថានភាពបានចាប់ផ្តើមប្រសើរឡើងវិញនៅត្រីមាសទី ៤ ក្នុងឆ្នាំ ២០២១ គោលការណ៍រឹតបន្តឹងត្រូវបានបន្ធូរបន្ថយនៅក្នុងតំបន់ជាច្រើន ។ អាជីវកម្មខ្នាតតូចជាច្រើនបានចាប់ផ្តើមសកម្មភាពឡើងវិញ ជាមួយគ្នានោះដែរពួកគេបានចាប់ផ្តើមស្វែងរកសេវាហិរញ្ញវត្ថុពី ហ្វឹស ហ្វាយនែន ផងដែរ ។ យើងសូមអរគុណជាពិសេសទៅដល់កិច្ចខិតខំប្រឹងប្រែងក្នុងការសម្រេចបាននូវគោលដៅអាជីវកម្មថ្មីនៅក្នុងត្រីមាសទី ៤ ដែល ហ្វឹស ហ្វាយនែន បានផ្តោតទៅលើទំហំនៃកម្ចីដែលជាលទ្ធផលផលបត្រឥណទានសរុបបានកើនឡើងដល់ ៣០ លានដុល្លា គិតជាភាគរយប្រមាណជា ៣០% ។ វាគឺជាសមិទ្ធផលដ៏អស្ចារ្យមួយ សម្រាប់ឆ្នាំ ២០២១ ដែលយើងចាត់ទុកថាជាឆ្នាំដែលប្រឈមដ៏តឹងតែងមួយ។

ស្របពេលដែលយើងកំពុងទប់ទល់ជាមួយវិបត្តិកូវីដ ជាមួយគ្នានេះផងដែរ ហ្វឹស ហ្វាយនែន ក៏បានខិតខំប្រឹងប្រែងក្នុងការរៀបចំខ្លួនសម្រាប់ការលូតលាស់ដ៏សំខាន់ នាពេលអនាគតផងដែរ ។ យើងបានអនុវត្តន៍យុទ្ធសាស្ត្រពីរក្នុងពេលតែមួយ ខណៈដែលដៃម្ខាងរបស់យើងកំពុងធ្វើការទាក់ទាញប្រភពទុនបន្ថែម ដៃម្ខាងទៀតបង្កើនការលក់តាមរយៈ ក្រុមអ្នកអភិវឌ្ឍន៍អចលនទ្រព្យ ។ យើងបានធ្វើការជាមួយដៃគូអន្តរជាតិមួយចំនួន ដើម្បីអោយប្រាកដថាយើងនឹងទទួលបាននូវទំហំកម្ចីដែលធំជាងមុន ជាមួយរយៈពេលវែង និងការប្រាក់ទាប ។ យើងក៏បានធ្វើការជាមួយអ្នកអភិវឌ្ឍន៍អចលនទ្រព្យជាច្រើនដែលមានអតិថិជន កំពុងបង់រំលោះលំនៅដ្ឋានជាមួយពួកគេ ដើម្បីផ្ទេរអតិថិជនទាំងនោះអោយមកប្រើប្រាស់សេវាកម្មីរបស់ ហ្វឹស ហ្វាយនែន វិញ ។





លោកស្រី ផុន សុថានី
អគ្គនាយិកា

តាមរយៈការលូតលាស់ដែលបានគ្រោងទុក ហ្វឹស ហ្វាយនែន នៅតែអាចបន្តនាំមកនូវផលប៉ះពាល់ជាវិជ្ជមានដល់សង្គម ដែលវាគឺជាចំណុចសំខាន់សម្រាប់យើង ដែលបានដើរស្របតាមបេសកម្មរបស់ខ្លួន ។ យើងមានជំនឿថា ការបង្កើនលទ្ធភាពក្នុងការទទួលបាននូវលំនៅដ្ឋានជាកម្មសិទ្ធិផ្ទាល់ខ្លួន តាមរយៈការផ្តល់នូវកម្ចីលំនៅដ្ឋានដែលមានតម្លៃសមរម្យ និងជំរុញអោយការប្រើប្រាស់អចលនទ្រព្យធ្វើជាទ្រព្យធានាមានប្រសិទ្ធិភាពជាងមុន ដែលវាគឺជាគន្លឹះសំខាន់មួយ ក្នុងការឆ្ពោះទៅរកភាពមានបាន។ គិតមកត្រឹមពេលនេះ យើងបានផ្តល់លទ្ធភាពដល់មនុស្សជាង ៥,000 គ្រួសារ ដើម្បីអោយពួកគេអាចទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន សាងសង់ និងជួសជុលផ្ទះ ។ អតិថិជនប្រមាណ ៦៥% ជាស្ត្រី នឹង ៤0% នៃអតិថិជនសរុបត្រូវបានយើងចាត់ទុកថាជាអ្នកដែលមានចំណូលទាប តិចជាង ៧00 ដុល្លារអាមេរិកក្នុងមួយខែ ។

នៅក្នុងឆ្នាំ ២០២១ នេះដែរ ដើម្បីបញ្ជាក់ ក៏ដូចជាការវាយតម្លៃទៅលើការប្តេជ្ញាចិត្តរបស់យើងក្នុងកិច្ចការការពារអតិថិជន ហ្វឹស ហ្វាយនែន បានអញ្ជើញស្ថាប័នវាយតម្លៃអន្តជាតិឯករាជ្យ M-Cril ដើម្បីត្រួតពិនិត្យទៅលើការអនុវត្តន៍របស់យើង ដោយផ្ទៀងផ្ទាត់ជាមួយនឹងស្តង់ដារថ្មីដែលចេញដោយ Cerise និង SPTF ។ Cerise និង SPTF ជាស្ថាប័នអន្តរជាតិ ដែលមិនគិតពីប្រាក់ចំណេញ ផ្តោតជាពិសេសទៅលើការគ្រប់គ្រងសមិទ្ធិផលសង្គម និងការការពារអតិថិជនរបស់ស្ថាប័នហិរញ្ញវត្ថុ ។ គោលការណ៍ទាំង ៧ ដែល ហ្វឹស ហ្វាយនែន បានអនុវត្តនោះមានដូចជា៖ ១. ការបង្កើតផលិតផល និងផ្តល់សេវាដែលត្រូវតាមលក្ខខណ្ឌអតិថិជន ២. ការការពារអតិថិជនពីបំណុលវណ្ឌករ ៣. ការផ្តល់នូវតម្លាភាពទៅដល់អតិថិជន ៤. ការកំណត់តម្លៃប្រកបដោយទំនួលខុសត្រូវ ៥. ផ្តល់ការគោរព និងយុត្តិធម៌ជូនដល់អតិថិជន ៦. ការផ្តល់យន្តការក្នុងការដោះស្រាយបណ្តឹងរបស់អតិថិជន ៧. ការរក្សាព័ត៌មានសម្ងាត់ជូនដល់អតិថិជន ។ ជាលទ្ធផល ហ្វឹស ហ្វាយនែន បានទទួលវិញ្ញាបនបត្រកម្រិតមាសដែលជាកម្រិតខ្ពស់បំផុត សម្រាប់ការអនុវត្តលើគោលការណ៍ការពារអតិថិជន ដែលជាស្តង់ដារថ្មី ពីស្ថាប័ន Cerise និង SPTF ។

ហ្វឹស ហ្វាយនែន នឹងនៅតែបន្តការគាំទ្រដល់ក្រុមគ្រួសារដែលមានចំណូលទាប និង មធ្យម តាមរយៈការផ្តល់នូវកម្ចីដែលមានរយៈពេលវែង ដើម្បីអោយពួកគាត់បានក្លាយជាម្ចាស់ផ្ទះដែលមានតម្លៃសមរម្យ និងនាំអោយមានស្ថេរភាពផ្នែកសេដ្ឋកិច្ច។ យើងខ្ញុំមានមោទនភាពជាខ្លាំងសម្រាប់ការបន្តគាំទ្រពីសំណាក់រាជរដ្ឋាភិបាល និងម្ចាស់គម្រោងអភិវឌ្ឍន៍អចលនទ្រព្យជាច្រើន ដែលបានផ្តោតការយកចិត្តទុកដាក់លើលំនៅដ្ឋានដែលមានតម្លៃសមរម្យ ជាហេតុធ្វើអោយយើងសំលឹងឃើញពីភាពវិជ្ជមានសម្រាប់ការលូតលាស់ក្នុងឆ្នាំ ២០២២។ យើងខ្ញុំមានជំនឿចិត្តថា នឹងទទួលបានជោគជ័យក្នុងការអនុវត្តយុទ្ធសាស្ត្រ ឆ្ពោះទៅរកភាពរីកចម្រើន ដោយផលបត្រឥណទាននឹងកើនឡើង ព្រមជាមួយភាពប្រសើរឡើងនៃសមិទ្ធផលហិរញ្ញវត្ថុ ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ អតិថិជន បុគ្គលិក អ្នកវិនិយោគប្រាក់កម្ចី ដៃគូអាជីវកម្ម និងស្ថាប័នដែលពាក់ពន្ធ័ ដែលបានចូលរួមចំណែកយ៉ាងច្រើនទៅក្នុងភាពជោគជ័យរបស់យើង ។

# អំពី ហ្វីស ហ្វាយនែន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វីស ហ្វាយនែន ភីអិលស៊ី គឺជាក្រុមហ៊ុនដែលបណ្តាក់ទុនរួមគ្នារវាង ក្រុមហ៊ុន ហ្វីស ហូម ភីអិលស៊ី ដែលមានទីតាំងក្នុងប្រទេសកម្ពុជា Phillip Capital ដែលមានទីតាំងក្នុងប្រទេសសិង្ហបុរី Insitor Fund ដែលមានទីតាំងក្នុងប្រទេសលុចសំបួរ មូលនិធិអភិវឌ្ឍន៍កម្ពុជា ឡាវ ( Cambodia-Laos Development Fund ) និង Norfund ដែលមានទីតាំងក្នុងប្រទេសន័រវេស។ ហ្វីស ហ្វាយនែន បានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី23 ខែមេសា ឆ្នាំ2009 ហើយបានក្លាយជាគ្រឹះស្ថានហិរញ្ញវត្ថុឯកទេស ក្នុងការផ្តល់ឥណទានផ្ទះសម្បែងមុនគេក្នុងប្រទេសកម្ពុជា។ ហ្វីស ហ្វាយនែន ផ្តោតយ៉ាងខ្លាំងទៅលើការផ្តល់ប្រាក់កម្ចីទិញផ្ទះ និងសាងសង់ផ្ទះរយៈពេលវែង ក៏ដូចជាកម្ចីអចលទ្រព្យធានារយៈពេលមធ្យម ទៅដល់គ្រួសារដែលមានចំណូលទាប និងមធ្យម ដែលភាគតិចណាស់ មានលទ្ធភាពប្រើប្រាស់សេវាកម្ចីលំនៅដ្ឋានរបស់គ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការនានា។ ភាគច្រើននៃធនាគារពាណិជ្ជផ្តល់សេវាដល់អតិថិជនដែលមានចំណូលខ្ពស់ ។

ក្រុមហ៊ុន ហ្វីស ហូម ភីអិលស៊ី ដែលជាក្រុមហ៊ុនស្ថាបនិក ហ្វីស ហ្វាយនែន បានធ្វើការសាកល្បង និងបានធ្វើឲ្យកាន់តែប្រសើរឡើងនូវគំនិតផ្តួចផ្តើមដំបូង ក្នុងការការផ្តល់ឥណទានផ្ទះសម្បែង ព្រមទាំងបានធ្វើការសិក្សាជាច្រើនទៅលើតម្រូវការទីផ្សារសម្រាប់ផលិតផលនេះ។ ទាំងនេះគឺជាមូលដ្ឋានគ្រឹះដែលនាំឲ្យ ហ្វីស ហ្វាយនែន រីកចម្រើនទៅមុខយ៉ាងឆាប់រហ័ស។

## ទស្សនៈវិជ្ជាអាជីវកម្មរបស់យើង

ទស្សនៈវិជ្ជាអាជីវកម្មរបស់យើងមានភាពសាមញ្ញ៖ **យើងគិតដូចជាអតិថិជន និងអនុវត្តដូចជាម្ចាស់**

ផ្តល់សេវា និងផលិតផល ដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារ

ផ្តល់នូវនីតិវិធីដែល មានភាពរហ័ស និងងាយស្រួល

ធ្វើប្រតិបត្តិការប្រកប ដោយភាពបត់បែន និងមានតម្លាភាព

បង្ហាញពីភាពសុចរិត ទៀងត្រង់ និងសីលធម៌ ក្នុងការអនុវត្តអាជីវកម្ម



## ចក្ខុវិស័យរបស់យើង

ជួយឲ្យក្រុមគ្រួសារនៅក្នុងប្រទេសកម្ពុជាដែលមានចំណូលមធ្យមកម្រិតទាប បានរស់នៅក្នុងសេចក្តីថ្លៃថ្នូរ សុវត្ថិភាព សុភមង្គល និងមានស្ថេរភាព តាមរយៈការផ្តល់លទ្ធភាពឲ្យពួកគាត់មានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន

## បេសកកម្មរបស់យើង

បង្កើតស្ថេរភាពសេដ្ឋកិច្ចនៃគ្រួសារកម្ពុជាដែលមានចំណូលមធ្យមកម្រិតទាប តាមរយៈការផ្តល់សេវាឥណទានដើម្បីឲ្យពួកគាត់ក្លាយជាម្ចាស់កម្មសិទ្ធិនៃផ្ទះសម្បែង

## គុណតម្លៃរបស់យើង

**សុចរិតភាព**
ដើម្បីសម្រេចបាននូវចក្ខុវិស័យរបស់យើង យើងប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ និងមានតម្លាភាពគ្រប់សកម្មភាពការងាររបស់យើង ។

**ការឆ្លើយតប**
យើងតែងនៅកៀកស្និទ្ធជាមួយអតិថិជនគ្រប់គ្រាន់ល្មម ដែលអាចឲ្យយើងផ្តល់ការយកចិត្តទុកដាក់ និងឆ្លើយតបតម្រូវការរបស់ពួកគាត់ទាន់ពេលវេលា ។ យើងក៏មានទំនួលខុសត្រូវគ្រប់ទង្វើរបស់យើង និងបើកចិត្តទូលាយក្នុងការទទួលយកការរិះគន់ដើម្បីស្តាបនាផងដែរ ។

**ភាពច្នៃប្រឌិតខ្ពស់**
យើងមានគំនិតច្នៃប្រឌិតខ្ពស់ ក្នុងការស្វែងរកដំណោះស្រាយដែលមានប្រសិទ្ធិភាពដើម្បីបម្រើអតិថិជនរបស់យើងឲ្យកាន់តែប្រសើរជាងមុន ។

**ភាពស្មើគ្នា**
យើងមានមោទនភាពចំពោះការគោរព ការមានជំនាញវិជ្ជាជីវៈច្បាស់លាស់ និងការបម្រើដល់អតិថិជនដោយស្មើភាព។

**ឧត្តមភាព**
ការងាររបស់យើង គឺធ្វើឡើងដោយអស់ពីកម្លាំងកាយចិត្ត។

# សមិទ្ធផលរបស់យើង

ហ៊ីស ហ្វាយនែន ជឿជាក់ថាការជួយអោយមនុស្សមានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន គឺជាកត្តាសំខាន់ក្នុងការជួយអោយពួកគាត់មានជីវិតប្រសើរឡើង ។ ស្ថេរភាពនៃការដែលមានផ្ទះផ្ទាល់ខ្លួន អាចជួយអោយគ្រួសារបានចំណាយពេលវេលា និងថាមពលទៅលើកត្តាផ្សេងទៀតដែលសំខាន់សម្រាប់ជីវិត ។ ក្មេងៗអាចចំណាយពេលសិក្សារៀនសូត្រ ចំណែកឯស្ត្រីអាចចាប់យករបរផ្សេងៗ ឬបម្រើការងារ ។ ទាំងនេះអាចជួយអោយទំនាក់ទំនងរវាងអ្នកជិតខាង និងសហគមន៍ក៏កាន់តែរឹងមាំ ។ ទំនាក់ទំនងដែលរឹងមាំនេះហើយ ដែលនាំមកនូវការគោរពរវាងគ្នានៅក្នុងគ្រួសារ ។ ការដែលមានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងអត្តសញ្ញាណបុគ្គល ។ សុវត្ថិភាព និងសន្តិសុខរបស់គ្រួសារនឹងកាន់តែកើនឡើង នៅពេលដែលពួកគាត់មានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ។

## ភាគរយអតិថិជនតាមភេទ



៦៥%    ៣៥%

## ចំនួនអតិថិជនសកម្មសរុប



**១.៨១២**

## ភាគរយអតិថិជនតាមទំហំចំណូលប្រចាំខែ






## ភាគរយអតិថិជនតាមប្រភពចំណូល




## ផលបត្រឥណទានតាមប្រវត្តិអតិថិជន



# អំពីផលិតផល

គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២១ ហ្វីស ហ្វាយនែន បានផ្តល់សេវាដល់ប្រជាជន ១.៨១២ គ្រួសារ ព្រមជាមួយផលបត្រឥណទានចំនួន ៣០.៥ លានដុល្លារ ។ យើងបានអភិវឌ្ឍផលិតផលថ្មីចំនួន ២ ដែលផលិតផលទី ១ គឺមានគោលដៅផ្តោតលើម្ចាស់គម្រោងអភិវឌ្ឍន៍ ដែលមានអតិថិជនកំពុងរំលោះជាមួយ ។ ចំពោះផលិតផលទី ២ មានគោលដៅផ្តោតលើអ្នកប្រកបរបរខ្នាតតូច ដែលបានប្រើប្រាស់លុយផ្ទាល់ខ្លួនធ្វើ ឬសាងសង់ផ្ទះ ហើយត្រូវការដើមទុនយកទៅបើក ឬពង្រីកអាជីវកម្ម ។

**កម្ចីទិញផ្ទះ** — ៣៦,៣% នៃចំនួនផលបត្រឥណទានសរុប — ៩១១ ចំនួនប្រាក់កម្ចីសកម្ម

**កម្ចីសាងសង់ ជួសជុលផ្ទះ** — ៦២០ ចំនួនប្រាក់កម្ចីសកម្ម — ១៨,៩% នៃចំនួនផលបត្រឥណទានសរុប

**កម្ចីទិញដី លំនៅដ្ឋាន** — ២៨,៥% នៃចំនួនផលបត្រឥណទានសរុប — ៧៦១ ចំនួនប្រាក់កម្ចីសកម្ម

**កម្ចីអចលនទ្រព្យធានា** — ៥៧៧ ចំនួនប្រាក់កម្ចីសកម្ម — ១៣,២% នៃចំនួនផលបត្រឥណទានសរុប

*កម្ចីអចលនទ្រព្យធានា ផ្តល់ជូនសម្រាប់តែអតិថិជនប៉ុណ្ណោះ*



# តំបន់ប្រតិបត្តិការ



# ហ្វីស ហ្វាយនែន ទទួលបាន វិញ្ញាបនបត្រ ស្តីពីការការពារអតិថិជន


M-CRIL
Incorporating EDA Rural Systems
Inclusive microeconomics

CLIENT PROTECTION CERTIFICATION

Issued to:

First Finance Plc.

#A15-17, St 271, Sangkat Tumnup Teuk,
Khan Chamkar Morn, Phnom Penh, Cambodia

*First Finance Plc. has been awarded the Gold Level Certification according to the new Client Protection Certification Framework promoted by SPTF and CERISE.*

*Certified by M-CRIL Limited*
*Level of compliance: Gold*
*Issue date: 03 March 2022*

Arpita Pal Agrawal
Managing Director

ហ្វីស ហ្វាយនែន បានទទួលវិញ្ញាបនបត្រកម្រិតមាសដែលជាកម្រិតខ្ពស់បំផុត សម្រាប់ការអនុវត្តលើគោលការណ៍ការពារអតិថិជន ដែលជាស្តង់ដារថ្មី ពីស្ថាប័ន Cerise និង SPTF ។ សូមបញ្ជាក់ថា Cerise និង SPTF ជាស្ថាប័នអន្តរជាតិ ដែលមិនគិតពីប្រាក់ចំណេញ ផ្តោតជាពិសេសទៅលើការគ្រប់គ្រងសមិទ្ធផលសង្គម និងការការពារអតិថិជនរបស់ស្ថាប័នហិរញ្ញវត្ថុ ។ ស្តង់ដារទាំង ៧ ដែល ហ្វីស ហ្វាយនែន បានអនុវត្តន៍នោះមានដូចជា៖ ១. ការបង្កើតផលិតផល និងផ្តល់សេវាដែលត្រូវតាមលក្ខខណ្ឌអតិថជន ២. ការការពារអតិថិជនពីបំណុលវណ្ណៈករ ៣. ការផ្តល់នូវតម្លាភាពទៅដល់អតិថិជន ៤. ការកំណត់តម្លៃប្រកបដោយទំនួលខុសត្រូវ ៥. ផ្តល់ការគោរព និងយុត្តិធម៌ជូនដល់អតិថិជន ៦. ការផ្តល់យន្តការក្នុងការដោះស្រាយបណ្តឹងរបស់អតិថិជន ៧. ការរក្សាព័ត៌មានសម្ងាត់ជូនដល់អតិថិជន ។

ហ្វីស ហ្វាយនែន ត្រូវបានបង្កើតឡើងដើម្បីហេតុផលផ្នែកសង្គម ។ ចាប់តាំងពីថ្ងៃកកើតរហូតមកដល់ពេលបច្ចុប្បន្ន យើងនៅតែបន្តការប្តេជ្ញាចិត្តផ្តល់កម្ចីលំនៅដ្ឋានទៅកាន់អ្នកដែលមានចំណូលទាប ដើម្បីអោយពួកគាត់បានក្លាយជាម្ចាស់ផ្ទះលើកដំបូងរបស់ខ្លួន ។ យើងបានធ្វើកិច្ចការងារល្អៗជាច្រើន ទាក់ទងទៅនឹងការការពារអតិថិជន ហើយវាជាការល្អដែលកិច្ចការនោះ ត្រូវបានវាយតម្លៃដោយភាគីទីបី។ ការវាយតម្លៃនេះ មានសារៈសំខាន់ណាស់ ជាពិសេសនៅក្នុងបរិបទមួយ ដែលលំនៅដ្ឋានដែលមានតំលៃសមរម្យ ហាក់នៅថ្មីនៅឡើយ។ វិញ្ញាបនបត្រនេះ បានបង្ហាញអោយឃើញកាន់តែច្បាស់ពីផលប៉ះពាល់វិជ្ជមានផ្នែកសង្គម និងការប្តេជ្ញាចិត្តរបស់យើងក្នុងការការពារអតិថិជន ។

គិតត្រឹមចុងឆ្នាំ ២០២១ ហ្វីស ហ្វាយនែន បានផ្តល់កម្ចីទៅកាន់ប្រជាជនដែលមានចំណូលទាបជាង ៧០០ដុល្លារក្នុង ១ខែ ប្រហែលជា ៤០% នៃអតិថិជនសរុប និង ប្រហែលជា ៤៨.៥% គឺជាអ្នកប្រកបរបររកស៊ីខ្នាតតូច ដូចជាអ្នកលក់ដូរនៅតាមដងផ្លូវជាដើម ពួកគាត់ទាំងនោះមិនមានរបាយការណ៍ចំណូលច្បាស់លាស់នោះទេ ទោះបីពេលខ្លះពួកគាត់មានចំណូលប្រហាក់ប្រហែលនឹងអ្នកធ្វើការក៏ដោយ ប៉ុន្តែពួកគាត់មិនភស្តុតាងដើម្បីបង្ហាញពីចំណូលទៅខាងធនាគារនោះទេ ។ អ្នកទាំងនោះហើយ គឺជាអតិថិជនគោលដៅដែល ហ្វីស ហ្វាយនែន ផ្តោតការយកចិត្តទុកដាក់ក្នុងការផ្តល់លទ្ធភាពអោយពួកគាត់អាចទទួលបានកម្ចីលំនៅដ្ឋាន ដើម្បីយកទៅទិញផ្ទះ សាងសង់ ឬជួសជុលផ្ទះដំបូងរបស់គាត់ ។





# ទិដ្ឋភាពទូទៅនៃអាជីវកម្ម

## ការពង្រឹងលើគុណភាព

រាល់សកម្មភាពប្រតិបត្តិការ និងការសម្រេចចិត្ត ហ្វីស ហ្វាយនែន តែងតែគិតពីហានិភ័យជាចម្បង ហើយទំលាប់នេះបានចាក់ស្រែះ និងក្លាយទៅជាវប្បធម៌អាជីវកម្មរបស់យើង។ ហ្វីស ហ្វាយនែន បានចាត់ទុកការគ្រប់គ្រងហានិភ័យ គឺជាធាតុសំខាន់មួយរបស់អាជីវកម្ម ។ ការគ្រប់គ្រងហានិភ័យពាក់ពន្ធ័នឹងការដែលអាចកំណត់បាននូវបញ្ហាដែលត្រូវប្រឈមបានលឿនក្នុងដំណាក់កាលដំបូង ដើម្បីផ្តល់នូវការយល់ឃើញឯករាជ្យសម្រាប់ការវាយតម្លៃទៅលើផលិតផល ការកំណត់យុទ្ធសាស្រ្ត ការវាយតម្លៃឥណទាន និងផ្នែកដ៏ទៃផ្សេងទៀត ។ នៅពេលដែលមានការកើនឡើងនៃវិស័យហិរញ្ញវត្ថុ គុណភាពឥណទានត្រូវបានផ្តោតការយកចិត្តទុកដាក់កាន់តែខ្ពស់ ហេតុដូចនេះហើយ យើងបានធ្វើបច្ចុប្បន្នភាពទៅលើនីតិវិធី និងដំណើរការវាយតម្លៃឥណទានជាប្រចាំឆ្នាំ អោយសមស្របទៅតាមស្ថានភាពជាក់ស្តែង ដែលយើងបានដាក់អោយផ្នែកសិក្សា និងវាយតម្លៃ នៅឯករាជ្យ។

ជាមួយនីតិវិធីដែលបានធ្វើបច្ចុប្បន្នភាពរួចហើយ ឥណទានដែលប្រឈមនឹងហានិភ័យត្រូវបានតាមដានត្រួតពិនិត្យ និងរាយការណ៍ជាប្រចាំ ។ យើងបានកំណត់នូវសញ្ញាបឋមលើឥណទានដែលមានបញ្ហ ដើម្បីនាំយកមកវិភាគ និងជជែកជាមួយភាគីដែលពាក់ពន្ធ័ ។ ប្រសិនបើចាំបាច់យើងនឹងផ្តល់នូវជំនួយណាមួយដែលសមស្រប ។

ជាលទ្ធផល កម្ចីដែលមិនដំណើរការបានធ្លាក់ចុះមួយកម្រិតពី ៣.៣% ក្នុងឆ្នាំ ២០២០ មកត្រឹម ២.៧៨% គិតត្រឹម ខែធ្នូ ២០២១ ខណៈដែលកម្ចីដែលបាត់បង់បានប្រមូលមកវិញប្រហែល ៤៣.៤៣% នៃចំនួនសរុប ។




**២,៧៨%↓**

**កម្ចីមិនដំណើរការ**

## ផ្នែកព័ត៌មានវិទ្យា

នាយកដ្ឋានព័ត៌មានវិទ្យា ផ្តល់សេវាចាំបាច់ផ្សេងៗពាក់ពន្ធ័ទៅនឹងព័ត៌មានវិទ្យាដូចជាការគាំទ្រផ្នែកប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្រាប់អ្នកគ្រប់គ្រង ការថែទាំហេដ្ឋារចនាសម្ពន្ធ័ដែលមានស្រាប់ ការពង្រឹងសន្តិសុខព័ត៌មានវិទ្យា និងការកែលម្អទៅការរក្សាទុកទិន្នន័យជាមួយ Synology 5 bay ។ នាយកដ្ឋានព័ត៌មានវិទ្យាក៏បានធ្វើបច្ចុប្បន្នភាពទៅលើប្រពន្ធ័ស្នូល ដូចជា CBC B2B Enquiry ពីជំនាន់ ៥ ទៅជំនាន់ ៦ ព្រមទាំងបង្កើតផលិតផលមួយចំនួនចូលទៅក្នុងប្រពន្ធ័ធនាគារស្នូល ។ បន្ថែមលើនេះ ក៏បានបង្កើតឧបករណ៍ និងរបាយការណ៍មួយចំនួនដើម្បីពន្លឿនការងារបញ្ចូលទិន្នន័យប្រចាំថ្ងៃចូលទៅក្នុងប្រពន្ធ័ និងក៏ដូចជារបាការណ៍សម្រាប់អ្នកគ្រប់គ្រង ។



**អភិវឌ្ឍន៍លើការរក្សាទុកទិន្នន័យជាមួយ SYNOLOGY 5 BAY**



**បង្កើតឧបករណ៍ពន្លឿនការបញ្ចូលទិន្នន័យ**

## ការបណ្តុះបណ្តាល និងអភិវឌ្ឍន៍

ការរៀនសូត្រនឹងមិនមានទីបញ្ចប់នោះទេ សម្រាប់មនុស្សគ្រប់រូប ដូច្នេះហើយក្រុមការងារ ផ្នែកបណ្តុះបណ្តាល និងអភិវឌ្ឍន៍ដែលពោរពេញដោយបទពិសោធន៍ បានត្រៀមខ្លួនជាស្រេចក្នុងការកសាងសមត្ថភាពបុគ្គលិកតាមរយៈការផ្តល់វគ្គបណ្តុះបណ្តាលខាងក្នុង និងខាងក្រៅស្ថាប័ន ។ ក្នុងស្ថានភាពវិបត្តិកូវីដ ហ្វីស ហ្វាយនែន បានសម្របខ្លួនទៅនឹងបរិបទថ្មី ដោយយើងបានផ្តល់វគ្គបណ្តុះបណ្តាលដល់បុគ្គលិកតាមប្រពន្ធ័អនឡាញ សម្រាប់ការពង្រឹងសមត្ថភាព ចំណេះដឹង និងជំនាញទៅលើផលិតផល និងសេវាកម្មដោយប្រកាន់គោលជំហរលើការអភិវឌ្ឍន៍ជាប្រចាំនេះ នឹងធ្វើអោយបុគ្គលិកមានលទ្ធភាពឆ្លើយតបទាន់ពេលវេលាស្របទៅតាមការរីកចម្រើនរបស់អាជីវ-កម្មដែលបានគ្រោងទុក និងក៏ដូចជាផ្តល់នូវភាពពេញចិត្តកម្រិតខ្ពស់ដល់អតិថិជន ។ យើងបានផ្តល់វគ្គបណ្តុះបណ្តាលមួយចំនួនដល់បុគ្គលិកចូលថ្មីចំនួន ២៥ នាក់ និងសម្របសម្រួលលើការបណ្តុះបណ្តាលខាងក្រៅជូនដល់បុគ្គលិកចំនួន ១៧ នាក់ ។



**ផ្តល់វគ្គបណ្តុះបណ្តាលតាមប្រពន្ធ័អនឡាញ ដល់ បុគ្គលិកចូលថ្មី និងសម្របសម្រួលវគ្គបណ្តុះបណ្តាលខាងក្រៅ**

## ផ្នែកទីផ្សារ និងអភិវឌ្ឍន៍ផលិតផល

ហ្វីស ហ្វាយនែន បានកំណត់ជំហរខ្លួនឯង ដោយធ្វើជាដៃគូរដំណោះស្រាយហិរញ្ញវត្ថុផ្នែកលំនៅដ្ឋានសម្រាប់អតិថិជនគោលដៅរបស់ខ្លួន ដោយផ្តល់សេវាអោយលើសពីសេវាហិរញ្ញវត្ថុ ដែលចំណុចនេះបានធ្វើអោយយើងខុសប្លែកពីស្ថាប័នដ៏ទៃ ។ រហូតមកដល់ពេលនេះ ផ្នែកបម្រើសេវាអតិថិជននៅតែបន្តផ្តល់សេវាប្រឹក្សាលើផ្នែកអចលនទ្រព្យទៅដល់សាធារណៈជន ចាប់តាំងពីផ្នែកនេះត្រូវបានបង្កើតនៅក្នុងឆ្នាំ ២០១៩ ។ យើងក៏បានបង្កើតអត្ថបទអប់រំមួយចំនួនទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងគន្លឹះសម្រាប់អ្នកដែលរកទិញផ្ទះជាលើកដំបូង ផ្សព្វផ្សាយតាមបណ្តាញអនឡាញរបស់យើង ។ យើងខ្នះខ្នែងក្នុងការផ្សព្វផ្សាយ ឈ្មោះរបស់ ហ្វីស ហ្វាយនែន ទៅកាន់សាធារណៈជន ដែលជាលទ្ធផល វេបសៃថ៍របស់ ហ្វីយ ហ្វាយនែន ត្រូវបង្ហាញលើគេ នៅក្នុង Google នៅពេលដែលវាយពាក្យទាក់ទងនឹងសេវាកម្ចីលំនៅដ្ឋាន ។ បន្ថែមលើនេះ យើងបានបង្កើតគ្រុប Facebook និងបញ្ចូល Telegram ចូលទៅក្នុងបណ្តាញទំនាក់ទំនងអនឡាញរបស់យើង ដើម្បីទទួលបានលទ្ធភាពបន្ថែមទៀតក្នុងការផ្សព្វផ្សាយផលិតផល ទៅកាន់អតិថិជនគោលដៅដែលប្រត្តិបត្តិការរបស់យើងបានពង្រីកទៅដល់ ។

**វេបសៃថ៍ ហ្វីស ហ្វាយនែន បង្ហាញលើគេ ក្នុង GOOGLE**

**បង្កើតផលិតផលថ្មី ២បន្ថែមទៀត**

ដើម្បីសម្របខ្លួនទៅវិបត្តិដែលកំពុងកើតឡើង យើងបានបង្កើតផលិតផល ២ បន្ថែមទៀត គឺកម្ចីសម្រាប់គម្រោងដៃគូ និងកម្ចីបង្កើនចំណូល។ កម្ចីម្ចាស់គម្រោងដៃគូ គឺផ្តល់ជូនដល់ម្ចាស់គម្រោងដៃគូដែលមានអតិថិជនកំពុងបង់រំលោះជាមួយ ។ សម្រាប់កម្ចីបង្កើតចំណូល គឺផ្តល់ជូនដល់អ្នកប្រកបរបរខ្នាតតូច ដែលមានផ្ទះរួចហើយ ពួកគាត់បានចំណាយលុយលើផ្ទះដំបូង ហើយខ្វះដើមទុនសម្រាប់ពង្រីក និងបង្កើតមុខរបរថ្មី ។

យើងជឿជាក់ថា សេវាអតិថិជន គឺជាចំណុចសំខាន់សម្រាប់ពង្រីកអាជីវកម្ម ដូច្នេះហើយយើងបានប្រមូលយកការផ្តល់យោបល់ និងមតិរិះគន់ដោយការយកចិត្តទុកដាក់ ដើម្បីអោយប្រាកដថាអតិថិជនរបស់យើងទទួលបាននូវសេវាកម្មដែលល្អនៅគ្រប់ចំណុចអន្តរកម្មរវាងពួកគាត់ជាមួយស្ថាប័នរបស់យើង ។ យើងក៏បានកែលម្អជាប្រចាំទៅនីតិវិធី និងដំណើរមួយចំនួន ។ កិច្ចការទាំងនេះ បានធ្វើអោយយើងក្លាយជាស្ថាប័នលេចធ្លោរមួយក្នុងទីផ្សារ ដែលបានផ្តល់នូវសេវាប្រកបដោយការច្នៃប្រឌិតខ្ពស់ទៅដល់អតិថិជន ។

## ផ្នែកលក់ និងប្រតិបត្តិការ

សម្រាប់ឆ្នាំ ២០២១ វិបត្តិកូវីដនៅតែរំខានដល់វិស័យធនាគារ ដែលធ្វើអោយប៉ះពាល់ដល់ការរីកចម្រើន ។ យើងបានព្យាករណ៍ទៅលើបញ្ហាប្រឈមដែលនឹងអាចកើតឡើងក្នុងវិបត្តិនេះ ហើយបានសម្រេចចិត្តកែប្រែទៅលើយុទ្ធសាស្ត្ររបស់យើង ចាប់តាំងពីដើមឆ្នាំ ២០២១ មក ។ ជាលទ្ធផលបានបញ្ជាក់អោយឃើញថា ការសម្រេចចិត្តរបស់យើងគឺត្រឹមត្រូវ ។ ក្រៅពីភាពខុសប្លែកនៃផលិតផល យើងក៏បានកែប្រែទៅលើយុទ្ធសាស្ត្រ និងយន្តការក្នុងការលក់ ដោយបានឈានមួយជំហ៊ានមុនគេនៅក្នុងទីផ្សារនេះ ហើយកិច្ចការទាំងនោះ បានជំរុញអោយមានការកើនឡើងលើផលបត្រឥណទានចំនួន ៣០% គឺ កើនឡើងពី ២៣.៦លានដុល្លារ ក្នុងឆ្នាំ ២០២០ ទៅដល់ ៣០.៥លានដុល្លារគិតត្រឹមចុងឆ្នាំ ២០២១ ។ ចំណែកឯចំនួនអតិថិជនបានកើនឡើង ២២% គឺកើនឡើងពី ១,៤៨៧ នៅឆ្នាំ ២០២០ ទៅ ១,៨១២ គ្រួសារនៅចុងឆ្នាំ ២០២១ ។

ការដែលផ្ទេរអតិថិជនពីការប្រើប្រាស់សេវាហិរញ្ញវត្ថុមិនផ្លូវការ អោយមកប្រើសេវាហិរញ្ញវត្ថុផ្លូវការបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ពួកគាត់ ។ អត្ថប្រយោជន៍មួយក្នុងចំណោមនោះ គឺអតិថិជនអាចយកផ្ទះរបស់គាត់ធ្វើជារបស់ទ្រព្យបញ្ចាំ នៅពេលណាមួយដែលគាត់ត្រូវការប្រាក់បន្ទាន់សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ដោយសារទ្រព្យបានកាត់ឈ្មោះទៅគាត់រួចរាល់ ។ គិតត្រឹមឆ្នាំ ២០២១ តាមរយៈកិច្ចសហការធ្វើជាដៃគូជាមួយគម្រោងអភិវឌ្ឍ ចំនួន ៧៧ គម្រោង យើងបានផ្ទេរអតិថិជនចំនួន ៧១៦ នាក់ អោយមកប្រើប្រាស់សេវាកម្ចីលំនៅដ្ឋានជាមួយ ហ្វីស ហ្វាយនែន ។

**៣០%**
**កំណើន ផលបត្រឥណទាន**

**២២%**
**កំណើន ចំនួនអតិថិជន**

**៧១៦ គ្រួសារ**

**ផ្ទេរអតិថិជន ៧១៦ នាក់ ពីការប្រើប្រាស់សេវាហិរញ្ញវត្ថុមិនផ្លូវការ មកសេវាហិរញ្ញវត្ថុផ្លូវការ**



# ការឆ្លើយតបទៅនឹងកូវីដ

២០២១ នៅតែជាឆ្នាំដែលច្របូកច្របល់សម្រាប់សកលលោក ភាពស្រាកស្រាន្តពីជំងឺកូវីដនៅតែមិនទាន់មានភាពច្បាស់លាស់នៅឡើយ ។ អតិថិជនរបស់យើងមួយចំនួន នៅតែទទួលការប៉ះពាល់ពីវិបត្តិនេះ ទាំងខាងផ្នែកការងារ និងផ្ទាល់ខ្លួន ។ យើងត្រូវតែរៀនសម្របខ្លួនទៅនឹងបរិយាកាសដែលតែងផ្លាស់ប្តូរនេះ បើទោះបីជានៅមានប្រភេទវីរុសបំលែងថ្មីៗ ក៏ដោយ ។ អ្វីដែលយើងបានរៀនពីបទពិសោធន៍ឆ្នាំមុនក្នុងការក្រោកឡើងមកវិញនោះ គឺការសម្របខ្លួន ដោយរាប់ចាប់ពីការអនុវត្តន៍តាមគោលការណ៍សុខាភិបាល រហូតដល់ការរៀបចំកម្ចីឡើងវិញ ។ យើងនៅតែបន្តការប្តេជ្ញាចិត្តរបស់យើងគាំទ្រដល់អតិថិជនដែលត្រូវការជំនួយ និងផ្តល់នូវសុវត្ថិភាពសម្រាប់ការមកប្រើប្រាស់សេវាកម្ចីរបស់យើង ។ យើងបានរៀបចំកម្ចីឡើងវិញ ដោយផ្តល់អាទិភាពដល់អតិថិជនដែលរងប៉ះពាល់ខ្លាំង ដូចជាអ្នកដែលជាប់ក្នុងតំបន់ដែលរាំងខ្ទប់ ឬអ្នកដែលកើតជម្ងឺកូវីដ ។ គិតត្រឹមឆ្នាំ ២០២១ យើងបានរៀបចំកម្ចីឡើងវិញ ដោយបន្ធូរបន្ថយចំនួនប្រាក់បង់ប្រចាំខែ ជូនដល់អតិថិជនចំនួន ២៥៥ គ្រួសារ គិតជាចំនួនឥណទាន ប្រមាណ ៣៨៣ កម្ចីជាមួយនឹងផលបត្រឥណទានប្រមាណជាង ៥.១ លានដុល្លារ ។

យើងបានផ្តល់អាទិភាពទៅលើសុខមាលភាពរបស់បុគ្គលិក តាមរយៈការអនុវត្តន៍យន្តការសុវត្ថិភាព និងមិនធ្វើអោយប៉ះពាល់ដល់ចំណូល និងសក្តានុពលរបស់បុគ្គលិកឡើយ ។ យើងបានលើកទឹកចិត្តដល់បុគ្គលិកដែលគ្រប់លក្ខខណ្ឌ អោយទៅទទួលវ៉ាក់សាំងកូវីដនៅតាមមណ្ឌលដែលរៀបចំដោយអាជ្ញាធរ ។ គិតត្រឹមឆ្នាំ ២០២១ គ្រប់បុគ្គលិកទាំងអស់របស់យើងបានទទួលវ៉ាក់សាំងកូវីដយ៉ាងហោចណាស់ ២ដូស ។ យើងបានចេញថ្លៃថ្នាំព្យាបាលកូវីដកំរិតស្រាល ដែលត្រូវបានអនុញ្ញាតិអោយព្យាបាលនៅផ្ទះដោយអាជ្ញាធរមានសមត្ថកិច្ច សម្រាប់បុគ្គលិក និងសមាជិកគ្រួសារដែលពួកគាត់បានដាក់ស្នើ ។

**៥,១៦ លានដុល្លារ**
**ផលបត្រឥណទាន កម្ចីរៀបចំឡើងវិញ**

**២៥៥ គ្រួសារ**
**ចំនួនអតិថិជនប៉ះពាល់ ដោយកូវីដ**

**៣៨៣ ឥណទាន**
**ចំនួនកម្ចីដែលរៀបចំ ឡើងវិញ**

**១០០% នៃបុគ្គលិក**
**ចំនួនបុគ្គលិកដែល ទទួលបានវ៉ាល់សាំង**

**ផ្តល់ជូនកញ្ចប់ថវិការ ចេញថ្លៃថ្នាំ ព្យាបាលកូវីដកម្រិតស្រាលដល់បុគ្គលិក និងសមាជិកគ្រួសារដែលបានដាក់ស្នើ**

# ដៃគូវិនិយោគ

## មូលធន




## ឥណទាន

www.oikocredit.coop

www.symbioticsgroup.com

www.blueorchard.com

www.norfund.no

www.triplejump.eu

www.waterequity.org

www.phillipbank.com.kh

www.ppcbank.com

www.lendahand.com

https://blueearth.capital



# រចនាសម្ព័ន្ធ ហ្វឹស ហ្វាយនែន





អ្នកស្រីគីមចេង កំពុងតុបតែងអាវប៉ាក់
នៅក្នុងហាងរបស់គាត់





# គាំទ្រដល់អាជីវកម្មរបស់អតិថិជនក្នុងកំឡុងពេលវិបត្តិ កូវីដ

អ្នកស្រី អ៊ី គីមចេង និងលោក ប៊ុនធឿន ជាស្វាមីបាន បើកហាងកាត់ដេរសំលៀកបំពាក់ ច្រើនជាង ១០ ឆ្នាំមកហើយ នៅក្នុងខេត្តកំពង់ចាម ។ អាជីវកម្មរបស់ពួកគាត់បានរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ ។ រហូតដល់បច្ចុប្បន្នអាជីវកម្មនេះ បានផ្តល់ការងារដល់មនុស្ស ១២ នាក់ នៅក្នុងសហគមន៍របស់ពួកគាត់។

ក្នុងគោលបំណងពង្រីកអាជីវកម្មអោយបានធំជាងមុន និងដើម្បីមានផ្ទះល្អសម្រាប់ក្រុមគ្រួសាររស់នៅ អ្នកស្រី គីមចេង និងស្វាមីបានសម្រេចចិត្តទិញផ្ទះថ្មីមួយក្នុងឆ្នាំ ២០១៨ ។ ដោយការផ្សំគ្នារវាង ប្រាក់សន្សំ និងកម្ចីទិញផ្ទះពី ហ្វីស ហ្វាយនែន ពួកគាត់បានទិញផ្ទះធំជាងមុន សម្រាប់គ្រួសារ និងអាជីវកម្មរបស់គាត់ ។ ក្នុងពេលជាមួយគ្នានោះដែរ ពួកគាត់បានសម្រេចចិត្តស្នើរកម្ចីបន្ថែមដើម្បីទិញសម្ភារៈ និងឧបករណ៍ផ្សេងៗបន្ថែមដើម្បីពង្រីកមុខរបរ ។ " ផ្ទះបានដើរតួនាទីសំខាន់ណាស់សម្រាប់ពួកយើង វាមិនគ្រាន់តែផ្តល់ជម្រកសម្រាប់គ្រួសារខ្ញុំនោះទេ វាថែមទាំងជាកន្លែងរកស៊ីដែលអាចផ្តល់ចំណូលជាប្រចាំដល់យើងថែមទៀត " លោក ប៊ុនធឿន បានមានប្រសាសន៍ ។

នៅក្នុងឆ្នាំ ២០២០ និង ២០២១ ប្រទេសកម្ពុជាបានទទួលរងវិបត្តិកូវីដ អាជីវកម្មមួយចំនួនបានបិទជាបណ្តោះអាសន្ន និងខ្លះទៀតបានក្ស័យធន ។ ដូចគ្នាទៅនឹងអាជីវកម្មផ្សេងៗទៀតដែរ អាជីវកម្មកាត់ដេររបស់អ្នកស្រី គីមចេង បានបាត់បង់ចំណូលប្រហែលជា ៨០% ។ លោក ប៊ុនធឿន ដែលជាស្វាមី បានមានប្រសាសន៍ថា៖ " វាជាពេលវេលាដ៏លំបាកមួយសម្រាប់ពួកយើង ។ ពេលនោះហិរញ្ញវត្ថុរបស់យើងមានបញ្ហា បើទោះបីជាយើងបានប្តូរពីការលក់ផ្ទាល់ មកជាការលក់លើអនឡាញក៏ដោយ " ។ លោកបានបន្ថែមថា " ខ្ញុំពិតជាអរគុណដល់ ហ្វីស ហ្វាយនែន ដែលបានជួយសម្រួលដោយបន្ថយចំនួនបង់សងប្រចាំខែរបស់ខ្ញុំ ក្នុងកំឡុងពេល ៦ ខែមកនេះ ជាហេតុធ្វើអោយខ្ញុំអាចសល់ប្រាក់ខ្លះសម្រាប់ឧបត្ថម្ភគ្រួសារ និងបង់ទៅអោយបុគ្គលិក ។ សំណាងល្អក្នុងត្រីមាសទី ៤ ចុងឆ្នាំ ២០២១ លែងមានការរាំងខ្ទប់បន្តទៅទៀត ឥឡូវនេះ អាជីវកម្មរបស់ខ្ញុំបានត្រឡប់មកដូចធម្មតាវិញហើយ " ។

# របាយការណ៍របស់សវនករឯករាជ្យ

(ដកស្រង់ពីរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២១ និងរបាយការណ៍របស់សវនករឯករាជ្យ)

## ជូនចំពោះភាគទុនិកនៃ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វឹស ហ្វាយនែន ភីអិលស៊ី

## មតិយោបល់

យើងខ្ញុំ បានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វឹស ហ្វាយនែន ភីអិលស៊ី

(ហៅកាត់ថា "ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ របាយការណ៍ចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន របាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួមទាំងសេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ។

តាមមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ("CIFRS for SMEs") និងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

## មូលដ្ឋាននៃមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរ-ជាតិនៃកម្ពុជា ("CISAs")។ ការទទួលខុសត្រូវរបស់យើងខ្ញុំ យោងតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា ត្រូវបានបរិយាយបន្ថែមនៅក្នុងផ្នែកនៃ "ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ" នៃរបាយការណ៍របស់យើងខ្ញុំ។ ។យើងខ្ញុំមានឯករាជ្យភាពពីក្រុមហ៊ុនដោយ អនុលោមតាមក្រុមប្រឹក្សាស្តង់ដារវិជ្ជាជីវៈគណនេយ្យអន្តរជាតិ ក្រមសីលធម៌ របស់គណនេយ្យករជំនាញ (រួមទាំងស្តង់ដារឯករាជ្យអន្តរជាតិ) ("IESBA Code") រួមជាមួយនិងតម្រូវការក្រម សីលធម៌ ដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ហើយយើងខ្ញុំបានបំពេញការទទួលខុសត្រូវទៅតាមតម្រូវការក្រមសីលធម៌ទាំងនោះ និង IESBA Code ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន គឺគ្រប់គ្រាន់ និងសមស្រប ដើម្បីផ្តល់មូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ។

## ព័ត៌មានផ្សេងៗ

គណៈគ្រប់គ្រងមានទំនួលខុសត្រូវទាំងស្រុងទៅលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗរួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ក៏ប៉ុន្តែមិនរាប់បញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកររបស់យើងខ្ញុំ ដែលទទួលបានមុនកាលបរិច្ឆេទនៃរបាយការណ៍សវនករ និងរបាយការណ៍ប្រចាំឆ្នាំ ដែលត្រូវបានរំពឹងថាធ្វើឡើងបន្ទាប់ពីកាលបរិច្ឆេទនោះឡើយ។

មតិយោបល់របស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗទេ។ យើងខ្ញុំមិនផ្តល់ការធានាក្នុងទម្រង់បែបណាមួយឡើយ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញ-វត្ថុ យើងខ្ញុំមានទំនួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានវិសមភាពជាសារវន្តជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុឬទេ ឬចំណេះដឹងរបស់យើងខ្ញុំ ដែលទទួលបានពីការធ្វើសវនកម្ម ថាតើព័ត៌មានទាំងនោះ អាចមានកំហុសឆ្គងជាសារវន្ត ឬទេ។

ប្រសិនបើ យោងតាមការងារដែលយើងបានអនុវត្តហើយ យើងខ្ញុំសន្និដ្ឋានថា បើមានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មាន ផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗ នេះទេ។

នៅពេលដែលយើងខ្ញុំអានរបាយការណ៍ប្រចាំឆ្នាំ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តណាមួយកើតមានឡើង យើងខ្ញុំត្រូវធ្វើការទាក់ទងជាមួយក្រុមប្រឹក្សាភិបាល និងទទួលខុសត្រូវលើបញ្ហាទាំងនេះដោយអនុលោមតាមការតម្រូវរបស់ CISA ៧២០ (បានធ្វើការកែតម្រូវ)។

## បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យផ្សេងទៀត ដែលបានផ្តល់នូវមតិយោបល់លើរបាយការណ៍ហិរញ្ញវត្ថុនាថ្ងៃទី២ ខែមេសា ឆ្នាំ២០២១។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ឱ្យបានត្រឹមត្រូវដោយអនុលោមតាមស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសខធុនតូច និងមធ្យម ("CIFRS for SMEs") និងការទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលក្រុមប្រឹក្សាភិបាលកំណត់ថា វាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុមិនឱ្យមានការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវចំពោះការវាយតម្លៃសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបន្តប្រតិបត្តិ-ការដោយផ្អែកលើមូលដ្ឋាននិរន្តរភាព ការលាតត្រដាង និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពជាមូលដ្ឋានគណនេយ្យ លុះត្រាតែក្រុមប្រឹក្សាភិបា-លមានគោលបំណងរំសាយក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬក៏គ្មានជម្រើសផ្សេង ប៉ុន្តែចាំបាច់ត្រូវធ្វើ។

ក្រុមប្រឹក្សាភិបាលមានការទទួលខុសត្រូវសម្រាប់ការត្រួតពិនិត្យលើដំណើរការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការទទួលខុសត្រូវរបស់សវនករទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដ៏សមហេតុផល ទៅលើរបាយការណ៍ហិរញ្ញវត្ថុដោយពុំមានលក្ខណៈខុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង និងការធ្វើរបាយការណ៍សវនកម្ម ដែលរួមមានមតិយោបល់របស់យើងខ្ញុំផងដែរ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាមួយដ៏ខ្ពស់ ប៉ុន្តែវាមិនបានធានាថាការធ្វើសវនកម្មដោយផ្អែកទៅលើស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជានឹងតែងតែរកឃើញនូវការរាយកា-រណ៍ខុសជាសារវន្តដែលមានឡើយ។ ការរាយការណ៍ខុសអាចកើតមានឡើងពីការក្លែងបន្លំ ឬ កំហុសឆ្គងដែលអាចចាត់ទុកថាជាសារ-វន្ត នៅពេលដែលកំហុសមួយ ឬ កំហុសរួមគ្នាបានធ្វើឱ្យប៉ះពាល់ដល់សេចក្តីសម្រេចចិត្ត ផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។

ផ្នែកមួយនៃជាការធ្វើសវនកម្ម ដោយយោងទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងអនុវត្តនូវវិជ្ជាជីវៈវិនិច្ឆ័យ និងរក្សាមជ្ឈធាតុនិយមប្រកបដោយវិជ្ជាជីវៈទៅលើការធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- កំណត់អត្តសញ្ញាណ និងវាយតម្លៃនូវហានិភ័យនៃការរាយការណ៍ខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុថាតើវាកើឡើង ដោយការក្លែងបន្លំ ឬកំហុសឆ្គងដោយអចេតនា រៀបចំនិងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ រួមទាំងការប្រមូលយកភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់ និងសមស្របដើម្បីជាមូលដ្ឋាន សម្រាប់បញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញដោយការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺធំជាងកំហុសឆ្គងដោយអចេតនាដោយសារតែការក្លែងបន្លំរួមបញ្ចូលទាំងការរួមគំនិត ការក្លែងបន្លំដោយចេតនា ការលុបចោលដោយចេតនា ការបង្ហាញខុស ឬការល្មើសទៅលើការត្រួតពិនិត្យផ្ទៃក្នុង។
- ធ្វើការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុងដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនីតិវិធីសវនកម្មដែលសមស្របទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុននោះទេ។
- ធ្វើការវាយតម្លៃភាពសមស្របលើគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មានក៏ដូចជាការបង្ហាញនានាដែលធ្វើឡើងដោយក្រុមប្រឹក្សាភិបាល។
- សន្និដ្ឋានដ៏សមស្របមួយទៅលើការប្រើប្រាស់របស់ក្រុមប្រឹក្សា-ភិបាលលើមូលដ្ឋាននិរន្តរភាពគណនេយ្យ ផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើភាពមិនប្រាកដប្រជាជាសារវន្តបានកើតឡើងទាក់ទិននឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលធ្វើឱ្យមានមន្ទិលសង្ស័យខ្លាំងទៅលើលទ្ធភាពការបន្តនិរន្តរភាពរបស់ក្រុមហ៊ុន។ ប្រសិនបើយើងសន្និដ្ឋានថា ភាពមិនប្រាកដប្រជាជាសារវន្តនឹងកើតមានឡើង យើងតម្រូវឱ្យធ្វើការលាតត្រដាងព័ត៌មានចាំបាច់ដើម្បីទាញការយកចិត្តទុកដាក់នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ទៅនឹងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬក៏ប្រសិនបើការលាតត្រដាងនោះមិនគ្រប់គ្រាន់ នោះមតិយោបល់មិនត្រឹមត្រូវនឹងត្រូវបានផ្តល់។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានគិតត្រឹមថ្ងៃនៃការចេញរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះបីយ៉ាងណាក៏ដោយស្ថានភាព ឬក៏ព្រឹត្តិការណ៍នាពេលអនាគតអាចបណ្តាលឱ្យក្រុមហ៊ុនមិនអាចបន្តប្រតិបត្តិការជានិរន្តរភាពបាន។
- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងមាតិការបស់របាយការ-ណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងការលាតត្រដាងនានា ថាតើរបាយកា-រណ៍ហិរញ្ញវត្ថុបង្ហាញនូវប្រតិបត្តិការ និងព្រឹត្តិការណ៍នានាដើម្បីបង្ហាញនូវភាពត្រឹមត្រូវសមស្របរបស់វា។

យើងខ្ញុំប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាភិបាលទៅលើបញ្ហាផ្សេងៗ កំណត់វិសាលភាព និងពេលវេលាក្នុងការធ្វើសវនកម្ម និងរបបគំហើញសវនកម្មសំខាន់ៗ រួមបញ្ចូលទាំងកង្វះខាតសំខាន់ៗមួយចំនួនទៅលើការគ្រប់គ្រងផ្ទៃក្នុងដែលយើងខ្ញុំបានរកឃើញអំឡុងពេលធ្វើសវនកម្ម។

Grant Thornton

ហ្គ្រេន សនធុន (ខេមបូឌា) លីមីធីត
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

Ronald C. Almera
នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២១

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១.៩៥០.៤១២ | ៧.៩៤៥.៩៧៨ | ២.៣១៧.៧៨០ | ៩.៣៧៥.៤២០ |
| ប្រាក់បញ្ញើតាមបទប្បញ្ញត្តិ | ១៨០.១០២ | ៧៣៣.៧៣៦ | ១៨០.១០២ | ៧២៨.៥១៣ |
| ឥណទានផ្តល់ជូនអតិថិជន - សុទ្ធ | ៣០.២៨៩.២២៦ | ១២៣.៣៩៨.៣០៧ | ២២.៩៣៤.៤៩៩ | ៩២.៧៧០.០៤៨ |
| ទ្រព្យសកម្មផ្សេងៗ | ៣៨២.៩៧៩ | ១.៥៦០.២៥៦ | ៣១៨.៨១១ | ១.២៨៩.៥៩០ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ៩៦.១៩៥ | ៣៩១.៨៩៨ | ១២៩.៨១១ | ៥២៥.០៨៥ |
| ទ្រព្យសកម្មអរូបី | ៤១.១២៨ | ១៦៧.៥៥៥ | ៧៣.២៦៥ | ២៩៦.៣៥៧ |
| ពន្ធពន្យារទ្រព្យសកម្ម- សុទ្ធ | ២៩.៦២៣ | ១២០.៦៨៤ | ២៩.៦២៣ | ១១៩.៨២៥ |
| **ទ្រព្យសកម្មសរុប** | **៣២.៩៦៩.៦៦៥** | **១៣៤.៣១៨.៤១៤** | **២៥.៩៨៣.៨៩១** | **១០៥.១០៤.៨៣៨** |
| **មូលធន និងបំណុល** | | | | |
| **បំណុល** | | | | |
| បំណុលផ្សេងៗ | ៣.៩២៧.៣៦៦ | ១៦.០០០.០៨៩ | ៦០២.៤២៥ | ២.៤៣៦.៨១០ |
| បំណុលពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន | ៤០.៨៧៦ | ១៦៦.៥២៩ | ២១.៦៦៧ | ៨៧.៦៤៣ |
| អត្ថប្រយោជន៍និយោជិត | ១១៣.៩១៤ | ៤៦៤.០៨៦ | ១៤១.៤៤០ | ៥៧២.១២៣ |
| ប្រាក់កម្ចី | ២១.៧១៩.៧៥៦ | ៨៨.៤៨៦.២៨៦ | ១៨.១៣៩.១៥៤ | ៧៣.៣៧២.៨៧៨ |
| **បំណុលសរុប** | **២៥.៨០១.៩១២** | **១០៥.១១៦.៩៩០** | **១៨.៩០៤.៦៨៦** | **៧៦.៤៦៩.៤៥៤** |
| **មូលធន** | | | | |
| ដើមទុន | ៣.៦០២.០៣៣ | ១៤.៤០៨.១៣២ | ៣.៦០២.០៣៣ | ១៤.៤០៨.១៣២ |
| ដើមទុនដែលលើស | ៨៧៩.៤៨២ | ៣.៥១៧.៩២៨ | ៨៧៩.៤៨២ | ៣.៥១៧.៩២៨ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ៤១៨.៦៦២ | ១.៦៩៣.៦២០ | ៣៤០.០១២ | ១.៣៧៣.៦៧២ |
| ចំណេញរក្សាទុក | ២.២៦៧.៥៧៦ | ៩.១៦០.០៤១ | ២.២៥៧.៦៧៨ | ៩.១១៩.៧៧៦ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ៤២១.៧០៣ | - | ២១៥.៨៧៦ |
| **មូលធនសរុប** | **៧.១៦៧.៧៥៣** | **២៩.២០១.៤២៤** | **៧.០៧៩.២០៥** | **២៨.៦៣៥.៣៨៤** |
| **មូលធន និងបំណុលសរុប** | **៣២.៩៦៩.៦៦៥** | **១៣៤.៣១៨.៤១៤** | **២៥.៩៨៣.៨៩១** | **១០៥.១០៤.៨៣៨** |



# របាយការណ៍ចំណូលលម្អិត

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២១

| | សម្រាប់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | សម្រាប់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលការប្រាក់ | ៣.៧៣៧.៣២៤ | ១៥.២០៣.៤៣៤ | ៣.៤៩៤.២៤៧ | ១៤.២៤៦.០៤៥ |
| ចំណាយការប្រាក់ | (១.៨១១.៧១៩) | (៧.៣៧០.០៧៣) | (១.៦៩២.៧៥៨) | (៦.៩០១.៣៧៤) |
| ចំណូលការប្រាក់សុទ្ធ | ១.៩២៥.៦០៥ | ៧.៨៣៣.៣៦១ | ១.៨០១.៤៨៩ | ៧.៣៤៤.៦៧១ |
| ចំណូលកម្រៃសេវា និងកម្រៃជើងសា | ៤១៦.៩៦៨ | ១.៦៩៦.២២៦ | ៣៨១.៧១៣ | ១.៥៥៦.២៤៤ |
| ចំណូលផ្សេងៗ | ១៤២.៥៩១ | ៥៨០.០៦០ | ៩២.៣៦៧ | ៣៧៦.៥៨០ |
| **ចំណូលប្រតិបត្តិការសុទ្ធ** | **២.៤៨៥.១៦៤** | **១០.១០៩.៦៤៧** | ២.២៧៥.៥៦៩ | ៩.២៧៧.៤៩៥ |
| ឱនភាពខាតបង់សុទ្ធលើទ្រព្យ | | | | |
| សកម្មហិរញ្ញវត្ថុ | (៣៨១.៦៧៣) | (១.៥៥២.៦៤៦) | (២០១.០៦០) | (៨១៩.៧២២) |
| ចំណាយបុគ្គលិក | (១.១៧១.០៧៨) | (៤.៧៦៣.៩៤៥) | (១.១២៩.៤១៨) | (៤.៦០៤.៦៣៧) |
| រំលស់ និងរំលស់ទ្រព្យអរូបី | (៩៩.៩០៩) | (៤០៦.៤៣០) | (១១៤.៩៤១) | (៤៦៨.៦១៤) |
| ចំណាយប្រតិបត្តិការ | (៦៦៤.៣២១) | (២.៧០២.៤៥៨) | (៦៧៥.២៣៨) | (២.៧៥២.៩៤៥) |
| **ចំណូលមុនបង់ពន្ធលើប្រាក់ចំណូល** | **១៦៨.១៨៣** | **៦៨៤.១៦៨** | ១៥៤.៩១២ | ៦៣១.៥៧៧ |
| ចំណាយពន្ធលើប្រាក់ចំណូល | (៧៩.៦៣៥) | (៣២៣.៩៥៥) | (៥៧.៨៤៣) | (២៣៥.៨២៦) |
| **ចំណូលក្នុងការិយបរិច្ឆេទសុទ្ធ** | **៨៨.៥៤៨** | **៣៦០.២១៣** | ៩៧.០៦៩ | ៣៩៥.៧៥១ |
| **ចំណូលលម្អិតផ្សេងៗ/(ខាត) -** | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | **២០៥.៨២៧** | - | (២១២.៥៧១) |
| **ចំណូលលម្អិតសរុបក្នុងការិយបរិច្ឆេទ** | **៨៨.៥៤៨** | **៥៦៦.០៤០** | ៩៧.០៦៩ | ១៨៣.១៨០ |

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២១

| | ដើមទុនភាគហ៊ុន | | ការកើនឡើងភាគហ៊ុន | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ចំណេញរក្សាទុក | | លម្អៀងពីការប្តូររូបិយប័ណ្ណ | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **សមតុល្យនាថ្ងៃទី០១ ខែមករា ឆ្នាំ២០២១** | ៣.៦០២.០៣៣ | ១៤.៤០៨.១៣២ | ៨៧៩.៤៨២ | ៣.៥១៧.៩២៨ | ៣៤០.០១២ | ១.៣៧៣.៦៧២ | ២.២៥៧.៦៧៨ | ៩.១១៩.៧៧៦ | ២១៥.៨៧៦ | ៧.០៧៩.២០៥ | ២៨.៦៣៥.៣៨៤ |
| ចំណេញក្នុងការិយបរិច្ឆេទ | - | - | - | - | - | - | ៨៨.៥៤៨ | ៣៦០.២១៣ | - | ៨៨.៥៤៨ | ៣៦០.២១៣ |
| ការផ្ទេរចេញពីទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | ៧៨.៦៥០ | ៣១៩.៩៤៨ | (៧៨.៦៥០) | (៣១៩.៩៤៨) | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | ២០៥.៩១០ | - | ២០៥.៩១០ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | ៣.៦០២.០៣៣ | ១៤.៤០៨.១៣២ | ៨៧៩.៤៨២ | ៣.៥១៧.៩២៨ | ៤១៨.៦៦២ | ១.៦៩៣.៦២០ | ២.២៦៧.៥៧៦ | ៩.១៦០.០៤១ | ៤២១.៧៨៦ | ៧.១៦៧.៧៥៣ | ២៩.២០១.៤២៤ |
| **សមតុល្យនាថ្ងៃទី០១ ខែមករា ឆ្នាំ២០២០** | ៣.៦០២.០៣៣ | ១៤.៤០៨.១៣២ | ៨៧៩.៤៨២ | ៣.៥១៧.៩២៨ | ៣១៦.៥០៥ | ១.២៧៧.៨៣៤ | ២.១៨៤.១១៦ | ៨.៨១៩.៨៦៣ | ៤២៨.៤៤៧ | ៦.៩៨២.១៣៦ | ២៨.៤៥២.២០៤ |
| ចំណេញក្នុងការិយបរិច្ឆេទ | - | - | - | - | - | - | ៩៧.០៦៩ | ៣៩៥.៧៥១ | - | ៩៧.០៦៩ | ៣៩៥.៧៥១ |
| ការផ្ទេរចេញពីទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | ២៣.៥០៧ | ៩៥.៨៣៨ | (២៣.៥០៧) | (៩៥.៨៣៨) | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | (២១២.៥៧១) | - | (២១២.៥៧១) |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០** | ៣.៦០២.០៣៣ | ១៤.៤០៨.១៣២ | ៨៧៩.៤៨២ | ៣.៥១៧.៩២៨ | ៣៤០.០១២ | ១.៣៧៣.៦៧២ | ២.២៥៧.៦៧៨ | ៩.១១៩.៧៧៦ | ២១៥.៨៧៦ | ៧.០៧៩.២០៥ | ២៨.៦៣៥.៣៨៤ |



# របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២១

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **សកម្មភាពប្រតិបត្តិការ** | | | | |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល | **១៦៨.១៨៣** | **៦៨៤.១៦៨** | ១៥៤.៩១២ | ៦៣១.៥៧៧ |
| **និយ័តកម្មសម្រាប់៖** | | | | |
| ចំណូលការប្រាក់សុទ្ធ | **(១.៩២៥.៦០៥)** | **(៧.៨៣៣.៣៦១)** | (១.៨០១.៤៨៩) | (៧.៣៤៤.៦៧១) |
| ឱនភាពខាតបង់សុទ្ធលើទ្រព្យសកម្មហិរញ្ញវត្ថុ | **៣៨១.៦៧៣** | **១.៥៥២.៦៤៦** | ២០១.០៦០ | ៨១៩.៧២២ |
| រំលស់ និងរំលស់ទ្រព្យអរូបី | **៩៩.៩០៩** | **៤០៦.៤៣០** | ១១៤.៩៤១ | ៤៦៨.៦១៤ |
| ការលុបចោលទ្រព្យសម្បត្តិ និងបរិក្ខារ | **១.២៩៥** | **៥.២៦៨** | ២.៩៤៦ | ១២.០១១ |
| សំវិធានលើអត្ថប្រយោជន៍និយោជិត | - | - | ១០.៩៦៥ | ៤៤.៧០៤ |
| **ប្រតិបត្តិការខាតមុនបម្រែបម្រួលដើមទុនបង្វិល** | **(១.២៧៤.៥៤៥)** | **(៥.១៨៤.៨៤៩)** | (១.៣១៦.៦៦៥) | (៥.៣៦៨.០៤៣) |
| **បម្រែបម្រួលដើមទុនបង្វិល៖** | | | | |
| **បម្រែបម្រួលសុទ្ធក្នុង៖** | | | | |
| ឥណទានផ្តល់ជូនអតិថិជន | **(៧.៧៣៦.៤០០)** | **(៣១.៤៧១.៦៧៥)** | ១.៦១១.១៧២ | ៦.៥៦៨.៧៤៨ |
| ទ្រព្យសកម្មផ្សេងៗ | **(៦៤.១៦៨)** | **(២៦១.០៣៥)** | ២៦១.៤០៩ | ១.០៦៥.៧៦៤ |
| បំណុលផ្សេងៗ | **៣.៣២៤.៩៤១** | **១៣.៥២៥.៨៦០** | (៣៤៦.៤៩២) | (១.៤១២.៦៤៨) |
| **សាច់ប្រាក់បានប្រើក្នុងសកម្មភាពប្រតិបត្តិការ** | **(៥.៧៥០.១៧២)** | **(២៣.៣៩១.៦៩៩)** | ២០៩.៤២៤ | ៨៥៣.៨២១ |
| ការប្រាក់ដែលបានទទួល | **៣.៧៣៧.៣២៤** | **១៥.២០៣.៤៣៤** | ៣.៤៩៩.២៤៧ | ១៤.២៤៦.០៤៥ |
| ការប្រាក់ដែលបានបង់ | **(១.៦២៧.៨៧៨)** | **(៦.៦២២.២០៨)** | (១.៧៧៤.២០៩) | (៧.២៣៣.៤៥០) |
| ពន្ធលើប្រាក់ចំណូលដែលបានបង់ | **(៦០.៤២៦)** | **(២៤៥.៨១៣)** | (៧៩.៦៦១) | (៣២៤.៧៧៨) |
| ការទូទាត់អត្ថប្រយោជន៍និយោជិត | **(២៧.៥២៦)** | **(១១១.៩៧៦)** | (៩.៧១២) | (៣៩.៥៩៦) |
| **សាច់ប្រាក់សុទ្ធបានប្រើក្នុង (មកពី) សកម្មភាពប្រតិបត្តិការ** | **(៣.៧២៨.៦៧៨)** | **(១៥.១៦៨.២៦២)** | ១.៨៤០.០៨៩ | ៧.៥០២.០៤២ |
| **សកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | (៣២.៩៧៦) | (១៣៤.១៤៦) | (២០.១០៣) | (៨១.៩៦០) |
| ការទិញទ្រព្យសកម្មអរូបី | (២.៤៧៥) | (១០.០៦៨) | (៦.៧៣៨) | (២៧.៤៧១) |
| **សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ** | (៣៥.៤៥១) | (១៤៤.២១៤) | (២៦.៨៤១) | (១០៩.៤៣១) |
| **សកម្មភាពហិរញ្ញប្បទាន** | | | | |
| ចំណូលបានមកពីប្រាក់កម្ចី | ១០.០៨៤.០៤៨ | ៤១.០២១.៩០៧ | ៤.១២៥.៩២៤ | ១៦.៨២១.៣៩២ |
| ការទូទាត់សងប្រាក់កម្ចី | (៦.៦៨៧.២៨៧) | (២៧.២០៣.៨៨៤) | (៥.៣៥៥.១២៩) | (២១.៨៣២.៨៦១) |
| **សាច់ប្រាក់សុទ្ធបានប្រើក្នុង (មកពី) សកម្មភាពហិរញ្ញប្បទាន** | ៣.៣៩៦.៧៦១ | ១៣.៨១៨.០២៣ | (១.២២៩.២០៥) | (៥.០១១.៤៦៩) |
| **កំណើនសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | (៣៦៧.៣៦៨) | (១.៤៩៤.៤៥៣) | ៥៨៤.០៤៣ | ២.៣៨១.១៤២ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមគ្រា | ២.៣១៧.៧៨០ | ៩.៣៧៥.៤២០ | ១.៧៣៣.៧៣៧ | ៧.០៦៤.៩៧៨ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ៦៥.០១១ | - | (៧០.៧០០) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងគ្រា** | ១.៩៥០.៤១២ | ៧.៩៤៥.៩៧៨ | ២.៣១៧.៧៨០ | ៩.៣៧៥.៤២០ |







# បំពេញក្តីសុបិន្ត ចង់មានផ្ទះជាកម្មសិទ្ធិ ផ្ទាល់ខ្លួន

បន្ទាប់ពីចំណាយពេលជាង១០ឆ្នាំធ្វើជាកម្មករចំណាកស្រុកទៅប្រទេសថៃ លោក អ៉ឹង ម៉ាប់ និង ភរិយារបស់គាត់ឈ្មោះ ធឿន សុខេង បានធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញ ក្នុងកំឡុងឆ្នាំ ២០១៦ ដោយរស់នៅក្នុងបន្ទប់ជួលតូចមួយ ក្នុងខេត្តប៉ៃលិន ភាគពាយព្យនៃប្រទេសកម្ពុជា ជាប់ព្រំដែនថៃ ។

ក្រោយពីត្រឡប់មកមាតុប្រទេសវិញ ជាមួយប្រាក់សន្សំដែលពួកគាត់មាន នៅកំឡុងពេលធ្វើការនៅក្នុងប្រទេសថៃ ពួកគេបានសម្រេចចិត្តទិញឡាន ដើម្បីប្រកបរបររត់តាក់ស៊ីដឹកភ្ញៀវទៅមក ប៉ៃលិន ភ្នំពេញ។ លោក អ៉ឹង ម៉ាប់មានប្រសាសន៍ថា៖ " មកដល់ស្រុកខ្មែរ ខ្ញុំបានប្រមូលលុយសន្សំទាំងអស់ដើម្បីទិញឡាន ចំណែកខ្ញុំ និង ភរិយាត្រូវរស់នៅក្នុងបន្ទប់ជួលតូចមួយ " ។ លោកបន្ថែមថា៖ " ខ្ញុំតែងសុបិន្តចង់មានផ្ទះមួយជារបស់ខ្លួនឯង " ។

នៅខែមករា ឆ្នាំ ២០២២ បុរីដៃគូ បានណែនាំ លោកអោយស្នើកម្ចីនៅ ហ្វឺស ហ្វាយនែន ។ គាត់បានសម្រេចចិត្តស្នើកម្ចីទិញដីចំនួន ២,៥០០ ដុល្លារ និង ស្នើបន្ថែម ១២,៧០០ ដុល្លារ ដើម្បីយកទៅសាងសង់ផ្ទះនៅលើដីនោះ ។ ក្តីសុបិន្តរបស់ពួកគេបានក្លាយជាការពិត ដោយផ្ទះថ្មីដែលកំពុងសាងសង់បានបញ្ចប់ប្រហែល ៨០% ទៅហើយ ។ ពួកគាត់គ្រោងនឹងចូលទៅរស់នៅក្នុងផ្ទះថ្មីក្នុងពេលឆាប់ៗនេះ បន្ទាប់ពីចំណាយពេលរស់នៅក្នុងបន្ទប់ជួលជាង ៦ឆ្នាំ ជាមួយកូនស្រីអាយុ ៤ឆ្នាំមក ។

ពួកគាត់បានថ្លែងអំណរគុណ ដល់កម្ចីលំនៅដ្ឋានខ្នាតតូចរយៈពេលវែងរបស់ ហ្វឺស ហ្វាយនែន ។ លោក អ៉ឹង ម៉ាប់ បាននិយាយថា " ការស្នើកម្ចីនៅ ហ្វឺស ហ្វាយនែន គឺបទពិសោធន៍លើកដំបូង សម្រាប់រូបខ្ញុំដែលប្រើប្រាស់សេវាឥណទានផ្លូវការ ហើយវាមិនស្មុគស្មាញដូចជាអ្វីដែលខ្ញុំបានលឺសោះ ។ ខ្ញុំសូមសសើរដល់សេវាកម្មរបស់ ហ្វឺស ហ្វាយនែន និងការជួយយកអាសាររបស់បុគ្គលិក " ។ គាត់បន្ថែមថា ប្រសិនបើមិនបានជួប ហ្វឺស ហ្វាយនែន ខ្ញុំប្រហែលជាចំណាយពេលនៅបន្ទប់ជួលច្រើនជាង ១០ ឆ្នាំទៀត ក៏ថាបាន ។

# ក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំ



## HANCO HALBERTSMA

### ប្រធានក្រុមប្រឹក្សាភិបាល

លោក Hanco Halbertsma គឺជាទីប្រឹក្សាផ្នែកយុទ្ធសាស្ត្រសម្រាប់ធនាគារ ស្ថាប័នហិរញ្ញវត្ថុ និងស្ថាប័នមីក្រូហិរញ្ញវត្ថុក្នុងប្រទេសកំពុងអភិវឌ្ឍន៍និងសម្រាប់អ្នកដែលចង់វិនិយោគលើស្ថាប័នហិរញ្ញវត្ថុ ។ ក្នុងរយៈពេលជាង20ឆ្នាំកន្លងទៅនេះ លោកបានធ្វើការក្នុងគម្រោងជាច្រើន ជាអ្នកជំនាញវិស័យហិរញ្ញវត្ថុ ដែលរួមមាន ផ្នែកមីក្រូហិរញ្ញវត្ថុ ផ្នែកធនាគារសម្រាប់អាជីវកម្ម ផ្នែកធនាគារសម្រាប់បុគ្គល ផ្នែកធនាគារសម្រាប់សហគ្រាសខ្នាតតូច ផ្នែកគ្រប់គ្រងហានិភ័យឥណទាន ផ្នែកអភិបាលកិច្ចសាជីវកម្ម និងផ្នែកហិរញ្ញប្បទាន ។

ក្នុងតួនាទីជាប្រធានក្រុមប្រឹក្សាភិបាលរបស់ហ្វីសហ្វាយនែន លោក Hanco ផ្តល់ការគាំទ្រផ្នែកយុទ្ធសាស្ត្រ ផ្នែកស្វែងរកមូលនិធិ ផ្នែកគ្រប់គ្រងហានិភ័យឥណទាន ផ្នែកហិរញ្ញវត្ថុ និងផ្នែកកសាងសមត្ថភាពបុគ្គលិក។ មុនពេលចាប់ផ្តើមជាមួយហ្វីសហ្វាយនែន លោកមានបទពិសោធន៍ក្នុងប្រទេសកម្ពុជាចំនួន៦ឆ្នាំមកហើយ ក្នុងនាមជាអភិបាលនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ដែលជាគ្រឹះ-ស្ថានមីក្រូហិរញ្ញវត្ថុធំជាងគេក្នុងប្រទេសកម្ពុជា ។ សព្វថ្ងៃលោកក៏ជាអភិបាលស្ថាប័ន Caspian Impact Investments Private Limited (CII) ដែលជាស្ថាប័នហិរញ្ញវត្ថុសម្រាប់សហគ្រាសខ្នាតតូចក្នុងប្រទេសឥណ្ឌា ដែលមានការរីកចម្រើនគួរឲ្យកត់សម្គាល់ ។

លោក Hanco គឺជាស្ថាបនិកក្រុមហ៊ុន Priority Project Limited (PPL) ដែលជាក្រុមហ៊ុនជំនាញក្នុងការប្រឹក្សាយោបល់ផ្នែកយុទ្ធសាស្ត្រ និង ផ្នែកប្រតិបត្តិការសម្រាប់ស្ថាប័នហិរញ្ញវត្ថុ និង វិនិយោគិនក្នុងតំបន់អាស៊ី ។ ក្រុមហ៊ុននេះត្រូវបានបង្កើតឡើង បន្ទាប់ពីលោកបានធ្វើការក្នុងក្រុមហ៊ុន ING Group អស់រយៈពេល១៦ឆ្នាំ ដែលក្នុងនោះរយៈពេល៨ឆ្នាំ គឺលោកបានធ្វើក្នុងក្រុមហ៊ុន ING-IGA ដែលជាក្រុមហ៊ុនពិគ្រោះយោបល់ក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ។

លោក Hanco បានបញ្ចប់ការសិក្សា ថ្នាក់អនុបណ្ឌិតជំនាញរដ្ឋបាលអាជីវកម្ម ហើយគាត់កំពុងធ្វើការក្នុងទីក្រុងហុងកុង។



## TALMAGE PAYNE

### អភិបាល

តំណាងម្ចាស់ភាគហ៊ុន ហ្វីស ហូម ភីអិលស៊ី

លោក Talmage Payne ជាសហគ្រិន និងអ្នកមានគំនិតច្នៃប្រឌិតមួយរូប ហើយសព្វថ្ងៃជាប្រធាននៃអង្គការសេចក្តីសង្ឃឹមពិភពលោកអន្តរជាតិប្រចាំនៅកម្ពុជា។ គាត់គឺជាស្ថាបនិក ហ្វីស ហ្វាយនែន និងអាជីវកម្មសង្គមជាច្រើនទៀត។ គាត់បានចំណាយពេលស្ទើរមួយជីវិតរបស់គាត់រស់ នៅទ្វីបអាស៊ី ដើម្បីធ្វើការទាំងក្នុងស្ថាប័នរកប្រាក់ចំណេញ និងស្ថាប័នមិនរកប្រាក់ចំណេញ ដែលផ្តល់ភាពវិជ្ជមានដល់សង្គម ។ គាត់ធ្លាប់ជានាយកប្រតិបត្តិនៃអង្គការ Hagar International (ការការពារ និង ការធ្វើឲ្យប្រសើរឡើងដល់អ្នកដែលរួចផុតពីការជួញដូរមនុស្ស) និងបានជួយបង្កើត Hagar ចំនួន ៩ប្រទេសដោយប្រើម៉ូដែល មានទាំងការរកប្រាក់ចំណេញ និងមិនរកប្រាក់ចំណេញ ។ លោកធ្លាប់ជានាយកអង្គការទស្សនៈពិភពលោកកម្ពុជា និងជាប្រធានស្ថាបនិក វីសិនហ្វាន់កម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ការងារមនុស្សធម៌របស់លោកជាច្រើនលើកតាមរយៈការបំពាក់មេដាយ ថ្នាក់មនុស្សជាតិពីរដង និងងារសហមេត្រី។ លោក បានសិក្សាមុខវិជ្ជាអភិវឌ្ឍន៍សេដ្ឋកិច្ចនៅសាកលវិទ្យាល័យ Wheaton College។



## NICHOLAS LAZOS

### អភិបាល

តំណាងម្ចាស់ភាគហ៊ុន Insitor Fund

លោក Nicholas Lazos គឺជាសហស្ថាបនិក និង ជានាយកនៃក្រុមហ៊ុន Insitor Impact Asia Fund លោក Nicholas បានធ្វើការនៅក្នុងតំបន់អាស៊ីខាងត្បូង និង អាស៊ីអាគ្នេយ៍អស់រយៈពេល10ឆ្នាំមកហើយ ក្នុងការជួយសហគ្រាសផ្នែកសង្គមក្នុងដំណាក់កាលចាប់ផ្តើមរបស់គេ ។ លោក Nicholas ទទួលខុសត្រូវលើវិនិយោគទុនធំៗ និង មានតួនាទីជាអភិបាលនៅក្នុងក្រុមហ៊ុនដែល Insitor បានវិនិយោគ ។ មុននឹងចូលបម្រើការនៅ Insitor លោក Nicholas គឺជាប្រធានចាត់ការទូទៅរបស់ក្រុមហ៊ុន ដែលផ្តល់ដំណោះស្រាយខាងគេហដ្ឋានដល់អ្នកដែលមានចំណូលទាបមុនគេបង្អស់នៅកម្ពុជា ។ លោកបានរៀបចំចាត់ចែងតាំងពីដំបូង និងអភិវឌ្ឍរហូតមានប្រតិ-បត្តិការពេញលេញ ។ គាត់ទទួលបានសញ្ញាប័ត្រពីរគឺផ្នែកគណិតវិទ្យានៅក្នុងកម្មវិធីវិទ្យាសាស្ត្រសង្គមពីសាកលវិទ្យាល័យ Northwestern University ។



## ONG TEONG HOON

### អភិបាល

តំណាងម្ចាស់ភាគហ៊ុន Phillip Capital

លោក Ong Teong Hoon មានបទពិសោធន៍ជាង ៣០ឆ្នាំ ក្នុងវិស័យធនាគារនៅអាស៊ី និងបទ-ពិសោធន៍ ប៉ុន្មានឆ្នាំចុងក្រោយក្នុងវិស័យមីក្រូ-ហិរញ្ញវត្ថុ។ លោក Teong Hoon គឺជានាយកប្រតិបត្តិជាន់ខ្ពស់ប្រចាំក្រុមហ៊ុន Phillip Capital ដែលជាក្រុមហ៊ុននាំមុខមួយនៅក្នុងអាស៊ី ហើយបច្ចុប្បន្នលោកជាអភិបាល និងជាតំណាងម្ចាស់ភាគហ៊ុននៅធនាគារ Phillip និងជាអភិបាលរបស់ក្រុមហ៊ុនធានារ៉ាប់រង Phillip ក្នុងប្រទេសកម្ពុជា ។ លោកជាប្រធានក្រុមប្រឹក្សាភិបាលសាលា Methodist ក្នុងប្រទេសកម្ពុជា និងមានតួនាទីជាថ្នាក់ដឹកនាំកំពូលនៃកម្មវិធី Youth and Detention Rehabilitation Program ។ លោក Teong Hoon ក៏ជាសមាជិកស្ថាបនិកក្រុមប្រឹក្សាភិបាលរបស់ហ្វីស ហ្វាយនែន និងបានធ្វើដំណើរជាមួយយើងឆ្លងកាត់ទាំងភាពលំបាក ការរីកចម្រើនខ្លាំង និងជ័យជំនះ។ គាត់ក៏ជាសមាជិកនៃវិទ្យាស្ថានធនាគារក្នុងទីក្រុងឡុងដ៏ផងដែរ (The Chartered Institute of Bankers in London) ។



## FAY CHETNAKARNKUL

### អភិបាល

Norfund

*លាលែងនៅថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០២១*

អ្នកស្រី Fay Chetnakarnkul ជានាយិកាផ្នែកវិនិយោគនិងជាប្រធាននៃ Norfund ប្រចាំនៅអាស៊ី ។ អ្នកស្រីមានតួនាទីក្នុងការគ្រប់គ្រង និងដឹកនាំផលបត្ររបស់ Norfund នៅអាស៊ី។ មុនមកកាន់ Norfund អ្នកស្រីបានបម្រើការងារនៅសហប្រតិ-បត្តិការហិរញ្ញវត្ថុអន្តរជាតិនិងធនាគាពិភពលោក។ អ្នកស្រីក៏មានបទពិសោធន៍ក្នុងវិស័យអភិវឌ្ឍន៍ហិរញ្ញវត្ថុតាមបណ្តាប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍ អាហ្វ្រិក អាមេរិកឡាទីន និងអឺរ៉ុបខាងកើត។

អ្នកស្រីបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ Johns Hopkins ផ្នែកសិក្សាអន្តរជាតិជាន់ខ្ពស់។



## PAUL FREER

### អភិបាលឯករាជ្យ

លោក Paul Freer មានបទពិសោធន៍ក្នុងតំណែងជាន់ខ្ពស់ជាង ២០ឆ្នាំជាមួយធនាគារអន្តរជាតិ និងមានប្រវត្តិទទួលបានជោគជ័យក្នុងការគ្រប់គ្រងគម្រោង ការអប់រំ ជាមួយវិស័យអង្គការមិនរកប្រាក់ចំណេញក្នុងប្រទេសកម្ពុជា ។

លោក Paul បានចាប់ផ្តើមអាជីពធនាគារដំបូង ក្នុងប្រទេសអង់គ្លេស មុនពេលចំណាយពេល១៥ឆ្នាំទៀតធ្វើការក្នុងប្រទេសកម្ពុជា និងប្រទេសឡាវក្នុងមុខដំណែងអ្នកគ្រប់គ្រងជាន់ខ្ពស់ ក្នុងអង្គការទាំងរកប្រាក់ចំណេញ និងមិនរកប្រាក់ចំណេញ ។ លោក Paul ធ្លាប់ជានាយកប្រតិបត្តិធនាគារ Standard Charted Bank ក្នុងប្រទេសកម្ពុជា នាយកគ្រប់គ្រងធនាគារ Phongsavanh Bank ក្នុងប្រទេសឡាវ និងជានាយកផ្នែក Retail Banking នៃធនាគារ ANZ Royal Bank (Cambodia)។ គាត់ក៏បានរួមចំណែកក្នុងការបង្កើតធនាគារ MARUHAN Japan BANK ក្នុងប្រទេសកម្ពុជាដោយគាត់បានបំរើការជាអគ្គនាយករង និងជាអ្នកចាត់ការទូទៅ ។

លោក Paul គឺជាសមាជិកគណៈកម្មាធិការផ្នែកហិរ-ញ្ញវត្ថុ និងសម្ភារបរិក្ខាររបស់សាលា International School of Phnom Penh និងជាអ្នកប្រឹក្សាឯករាជ្យលើវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុជាមួយធនាគារពិភពលោក ក៏ដូចជាអង្គការដ៏ទៃទៀត។

លោក Paul ទទួលបានសញ្ញាបត្រអនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្មពីសាកលវិទ្យាល័យ Southampton Business School របស់ប្រទេសអង់គ្លេស។

# ក្រុមប្រឹក្សាភិបាល



## DAVID LITTLEJOHN

### អភិបាលឯករាជ្យ

ធ្លាប់បម្រើការងារផ្នែកលក់ក្នុងប្រទេសសិង្ហបុរី និងទីក្រុងបាងកក ជាង 20ឆ្នាំ លោក David Littlejohn ដែលមានកំណើតក្នុងប្រទេសញូហ្សេលែន បានមកប្រទេសកម្ពុជាកាលពី 6 ឆ្នាំមុន ដោយបានចូលបម្រើការងារជាប្រធានផ្នែកលក់ និងទីផ្សារឲ្យក្រុមហ៊ុន Comin Khmere ដែលជាក្រុមហ៊ុនឈានមុខ ក្នុងការផ្តល់ដំណោះស្រាយផ្នែកវិស្វកម្មក្នុងប្រទេសកម្ពុជា។ ក្រុមហ៊ុន Comin Khmere រៀបចំ អនុវត្ត និងថែទាំប្រព័ន្ធ ក្នុងវិស័យវិស្វកម្មអគ្គិសនី និងគ្រឿងយន្ត ម៉ាស៊ីនត្រជាក់ និងទូទឹកកក ថាមពលមិនកកើត និងថាមពលកកើតឡើងវិញ ការរៀបចំប្រព័ន្ធទឹក ការការពារអគ្គិភ័យ ហេដ្ឋារចនាសម្ព័ន្ធបណ្តាញ សន្តិសុខ និងស្វ័យប្រវត្តិកម្ម និងដំណោះស្រាយ ផ្នែកជណ្តើរយន្ត។



## JOSHUA MORRIS

### អ្នកអង្កេត

តំណាងម្ចាស់ភាគហ៊ុន CLDF

លោក Joshua Morris ជាដៃគូរស្ថាបនិក និងជានាយកគ្រប់គ្រងនៃ Emerging Markets Investments (EMI) ជាអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគដែលមានមូលដ្ឋាននៅប្រទេសកម្ពុជា និងដែលគ្រប់គ្រងមូលនិធិ Cambodia-Laos Development Fund ។ មុនពេលបង្កើត EMI លោក Joshua បានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍវិស័យឯកជន និងផ្តល់ប្រឹក្សាអាជីវកម្មនៅក្នុងអាស៊ីអាគ្នេយ៍ តាមរយៈតួនាទីរបស់លោកជាសហស្ថាបនិកក្រុមហ៊ុន Emerging Markets Consulting ដែលជាក្រុមហ៊ុនប្អូនរបស់ក្រុមហ៊ុន EMI ។

មុនពេលប្តូរមករស់នៅកម្ពុជា ក្នុងឆ្នាំ 2004 លោក Joshua មានការងារជាអ្នកគ្រប់គ្រងជាន់ខ្ពស់ផ្នែកទីផ្សារ និងអភិវឌ្ឍន៍សាជីវកម្មនៃក្រុមហ៊ុនបច្ចេកវិទ្យាដែលទើបចាប់ផ្តើម និង ជាក្រុមហ៊ុនពាណិជ្ជកម្មអេឡិចត្រូនិក ដែលចុះបញ្ជីទីផ្សារភាគហ៊ុនជាមួយ NASDQ ។

លោក Joshua ទទួលបានសញ្ញាបត្រអនុបណ្ឌិតពីសាកលវិទ្យាល័យ Harvard Business School ឆ្នាំ1998 និងសញ្ញាបត្របរិញ្ញាបត្រកិត្តិយសពី Harvard University ក្នុងឆ្នាំ1992 ។





មន្ត្រីប្រឹក្សាឥណទាន ផ្តល់ប្រឹក្សាពីផលិតផលជូនដល់អតិថិជន នៅក្នុងហាងកាត់ដេរសំលៀកបំពាក់របស់គាត់

# គណៈគ្រប់គ្រង



## ជុន សុថានី
### អគ្គនាយិកាប្រតិបត្តិ

អ្នកស្រី ជុន សុថានី បានចាប់ផ្តើមអាជីពជាមួយ អង្គការទស្សនៈពិភពលោក ជាសវនករផ្ទៃក្នុង នៅក្នុងឆ្នាំ 2002 ។ ចាប់តាំងពីពេលនោះមក លោកស្រី មានការរីកចម្រើនយ៉ាងលឿនជាមួយ តួនាទីជាច្រើន រួមមានការគ្រប់គ្រងការបង្កើត គម្រោង ការបង្កើតសំណើរ (Propsoal Development) ការពិនិត្យការរីកចម្រើន និងការកសាង ទំនាក់ទំនងជាមួយម្ចាស់ជំនួយ ។
នៅឆ្នាំ2007 លោកស្រី បានក្លាយជាប្រធានផ្នែក អភិវឌ្ឍន៍ពាណិជ្ជកម្មនៃ វីសិនហ្វាន់ កម្ពុជា ដែល លោកស្រីទទួលខុសត្រូវផ្នែករកមូលនិធិ ផ្នែក ទីផ្សារ ផ្នែកទំនាក់ទំនង និងអភិវឌ្ឍន៍ផលិតផល ។ ឆ្នាំ2008 លោកស្រីផ្លាស់ទៅក្រុមហ៊ុន វីង ដែលនៅ ទីនោះ លោកស្រីបានបង្កើតផែនការយុទ្ធសាស្រ្ត និងគ្រប់គ្រងការលក់ រួមទាំងការលើកទឹកចិត្តនិង ពង្រីកភ្នាក់ងារលក់ជាង 900 នាក់ ។ លោកស្រី សុថានី បានចូលបម្រើការជាមួយ ហ្វីស ហ្វាយនែន នៅឆ្នាំ 2011 ជានាយិកាផ្នែកហិរញ្ញវត្ថុ ហើយ ត្រូវបានតែងតាំងជាអគ្គនាយិកាប្រតិបត្តិ នៅខែ សីហា ឆ្នាំ 2014 ។
លោកស្រី សុថានី បានទទួលបរិញ្ញាបត្រគ្រប់គ្រង ផ្នែកគណនេយ្យ និងបានបន្តអនុបណ្ឌិតអភិវឌ្ឍអង្គ-ភាពក្នុងការគ្រប់គ្រងកម្ចីខ្នាតតូច ។



## ហេង សក្កា
### ប្រធាននាយដ្ឋានឥណទាន

លោក ហេង សក្កា ជាសមាជិកដែលបានធ្វើការយូរ ជាងគេជាមួយ ហ្វីស ហ្វាយនែន ។ ចាប់ផ្តើមដំបូង ជាមន្ត្រីរដ្ឋបាលឥណទាននៅឆ្នាំ 2009 ពេលដែល ហ្វីស ហ្វាយនែន ទទួលបានអាជ្ញាប័ណ្ណ របស់ ខ្លួន ។ លោក សក្កា បានរីកចម្រើនជាមួយតួនាទី មួយចំនួន និងបានទទួលការតែងតាំងជាប្រធាន សាខាភ្នំពេញនៅឆ្នាំ 2013 និងជាប្រធាននាយ-កដ្ឋានប្រតិបត្តិការនៅខែ ឧសភា ឆ្នាំ 2015។ គាត់ មានចំណេះដឹងទូលំទូលាយអំពីក្រុងភ្នំពេញ ព្រោះ គាត់រស់នៅទីនេះពេញមួយជីវិតរបស់គាត់ តែគាត់ក៏ មានបទពិសោធន៍ ធ្វើដំណើរទៅក្រៅប្រទេសផងដែរ ។ លោក សក្កា ទទួលបានបរិញ្ញាបត្រពីរ គឺគណនេយ្យ ហិរញ្ញវត្ថុ និង ភាសាបារាំង ។ បច្ចុប្បន្នគាត់កំពុង បញ្ចប់អនុបណ្ឌិតគ្រប់គ្រងហានិភ័យ ផ្នែកធានា រ៉ាប់រង ហិរញ្ញវត្ថុ និងធនាគារ ។



## ឆេង ប៊ុនហៀង
### ប្រធាននាយកដ្ឋានគ្រប់គ្រងផ្នែកលក់

លោក ប៊ុនហៀង បានចូលបម្រើការនៅ ហ្វីស ហ្វាយនែន នៅខែវិច្ឆិកា ឆ្នាំ 2018 ជាប្រធានគ្រប់ គ្រងផ្នែកលក់។ គាត់បានចាប់ផ្តើមការងារនៅ អម្រឹត ក្នុងឆ្នាំ 2003 ដែលទីនោះគាត់បានធ្វើការនៅក្នុង ថ្នាក់គ្រប់គ្រងរយៈពេល 10ឆ្នាំ ។ ប្រវត្តិការងាររបស់ លោកបានចាប់ផ្តើមពីថ្នាក់មូលដ្ឋាន គឺចាប់ពីតួនាទី ជាអ្នកបើកបរ បេឡា បុគ្គលិកឥណទាន អនុប្រធាន សាខា ប្រធានសាខា និងអនុប្រធានសាខាខេត្ត ប្រធានសាខាខេត្ត និងអនុប្រធានអភិវឌ្ឍផលិតផល ឥណទាន ។
លោក ប៊ុនហៀង បានបញ្ចប់បរិញ្ញាបត្រផ្នែករដ្ឋបាល ពាណិជ្ជកម្ម ជំនាញគណនេយ្យ និងហិរញ្ញវត្ថុក្នុងឆ្នាំ 2007 ពីសាកលវិទ្យាល័យ បៀលប្រាយ និងភាសា អង់គ្លេសពីសាកលវិទ្យាល័យបញ្ញាសាស្រ្ត។



## វ៉េត វរលក្ខណ៍
### ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ

អ្នកស្រី វរលក្ខណ៍ មានបទពិសោធន៍ជាង10ឆ្នាំ ផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ ។ វរលក្ខណ៍ ធ្លាប់បម្រើការងារនៅតាមក្រុមហ៊ុនគណនេយ្យ ក្រុមហ៊ុនធានារ៉ាប់រង និងអាជីវកម្មទូទៅ ។ អ្នកស្រី ចូលបម្រើការងារនៅក្នុង ហ្វីស ហ្វាយនែន នា ឆ្នាំ2012 ។ វរលក្ខណ៍ បានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រ ផ្នែកហិរញ្ញវត្ថុ និងធនាគារ អនុបណ្ឌិតផ្នែកគ្រប់គ្រង ពាណិជ្ជកម្ម និង បច្ចុប្បន្នកំពុងបន្តការសិក្សាថ្នាក់ ACCA ។



## សាំង វណ្ណឌី
### ប្រធាននាយកដ្ឋានទីផ្សារ

លោក វណ្ណឌី បានបញ្ចប់បរិញ្ញាបត្រផ្នែកប្រព័ន្ធព័ត៌-មានវិទ្យាគ្រប់គ្រង ពីសាកលវិទ្យាល័យជាតិគ្រប់-គ្រងក្នុងឆ្នាំ2002។ មុនមកចូលរួមជាមួយ ហ្វីស ហ្វាយនែន គាត់បានបំរើការជាអ្នកសម្របសម្រួល ផ្នែកទីផ្សារ និងទំនាក់ទំនងរយៈពេល 2ឆ្នាំ និង បន្ទាប់មកជាអ្នកគ្រប់គ្រងផ្នែកផលិតសម្ភារៈផ្សព្វ ផ្សាយជាង 7 ឆ្នាំ នៅ វីសិនហ្វាន់ កម្ពុជា ដែលគាត់ ជាអ្នកគ្រប់គ្រង និងអភិវឌ្ឍន៍យុទ្ធសាស្រ្តប្រេនដ៏ និងយុទ្ធសាស្រ្តទំនាក់ទំនងទីផ្សារ។ លោក វណ្ណឌី ក៏មានបទពិសោធន៍ជាច្រើនឆ្នាំ ជាមួយក្រុមហ៊ុន ផ្សព្វផ្សាយពាណិជ្ជកម្ម និងអង្គការអន្តរជាតិផងដែរ ។ គាត់ចូលរួមជាមួយ ហ្វីស ហ្វាយនែន ក្នុង ខែមីនា ឆ្នាំ 2016 ជាប្រធានផ្នែកទីផ្សារ ។



## ច្រឹក ស៊ីណេត
### ប្រធាននាយកដ្ឋានព័ត៌មានវិទ្យា

លោក ស៊ីណេត បានបម្រើការអស់រយៈពេលច្រើន ជាងមួយទសវត្សរ៍ ហើយក្នុងកិច្ចការអនុវត្តប្រព័ន្ធ បណ្តាញកុំព្យូទ័រ ប្រព័ន្ធសុវត្ថិភាពព័ត៌មានវិទ្យា ប្រព័ន្ធគ្រប់គ្រងព័ត៌មាន ក៏ដូចជាការងារយុទ្ធសាស្រ្ត និងគម្រោងព័ត៌មានវិទ្យាផ្សេងៗ ជាមួយស្ថាប័ន មីក្រូហិរញ្ញវត្ថុ ។ គាត់បានចូលរួមជាមួយ ហ្វីស ហ្វាយនែន ជាប្រធានផ្នែកព័ត៌មានវិទ្យា នាខែមេសា ឆ្នាំ 2016 ។ កាលពីមុន គាត់ធ្លាប់ជាប្រធានគាំទ្រ កម្មវិធីព័ត៌មានវិទ្យា ដែលមានតួនាទីសម្របសម្រួល រវាងបុគ្គលិក បច្ចេកទេស ព័ត៌មានវិទ្យា និង បុគ្គលិកផ្នែកអាជីវកម្មនៅអម្រឹត និងធ្លាប់ជាប្រធាន គាំទ្រកម្មវិធី និងបច្ចេកទេសនៅ វីសិនហ្វាន់កម្ពុជា។ គាត់បានទទួលបរិញ្ញាបត្រព័ត៌មានវិទ្យា ពីសាកល វិទ្យាល័យបៀលប្រាយ នៅទីក្រុងភ្នំពេញ។

# គណៈគ្រប់គ្រង





## ស៊ាន ម៉េងសែ
### ប្រធាននាយកដ្ឋាន
### រដ្ឋបាលនិងធនធានមនុស្ស

លោក ម៉េងសែ មានការរីកចម្រើនខ្ពស់ក្នុងអាជីពការងារ ។ លោកបានប្រលូកចូលក្នុងវិស័យការងារបានជាង 10 ឆ្នាំ ដោយចាប់ផ្តើមពីកម្រិតបុគ្គលិកធម្មតា រហូតដល់កម្រិតគ្រប់គ្រងក្នុងផ្នែកបណ្តុះបណ្តាល និងអភិវឌ្ឍន៍ និងផ្នែកគ្រប់គ្រងធនធានមនុស្ស ដោយលោកមានបទពិសោធន៏ និងជំនាញពាក់ព័ន្ធនឹងផ្នែកជ្រើសរើសបុគ្គលិក បង្កើតគោលនយោបាយធនធានមនុស្ស រដ្ឋបាលបុគ្គលិក សម្របសម្រួលកិច្ចការធនធានមនុស្ស សំណងទូទាត់ ។ល។ លោកមានអត្តចរិតល្អប្រសើរ មានភាពអត់ធ្មត់ និងការតាំងចិត្តខ្ពស់។ អំពីការសិក្សា លោកបានទទួលអាហារូបករណ៍កម្រិតបរិញ្ញាបត្រពីសាកលវិទ្យាល័យជាតិគ្រប់គ្រងក្នុងឆ្នាំ 2000 និងបានបញ្ចប់បរិញ្ញាបត្រផ្នែកគ្រប់គ្រងក្នុងឆ្នាំ 2004 និងបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រង ក្នុងឆ្នាំ 2009 ។

## ហួ ណាំគា
### ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង

លោក ណាំគា មានបទពិសោធន៍ជាង 10 ឆ្នាំ ផ្នែកសវនកម្ម និងហិរញ្ញវត្ថុ ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ ជាមួយក្រុមហ៊ុនប្រឹក្សាយោបល់ និងក្រុមហ៊ុនអន្តរជាតិ ។ បទពិសោធន៍របស់គាត់ គឺពាក់ព័ន្ធនឹងការត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់ លើការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង អភិបាលកិច្ច និងស៊ើបអង្កេតលើការកេងបន្លំនៅក្នុងស្ថាប័ន ។ មុនពេលចូលរួមជាមួយ ហ្វឹស ហ្វាយនែន លោកបានកាន់តួនាទីជាច្រើនរួមមាន ប្រធានផ្នែកសវនកម្ម អនុប្រធានត្រួតពិនិត្យហិរញ្ញវត្ថុ និងតួនាទីមួយចំនួនក្នុងតំណែងគ្រប់គ្រង ។

លោក ណាំគា បានបញ្ចប់បរិញ្ញាបត្រផ្នែកធនាគារ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ហើយគាត់កំពុងបន្តការបញ្ចាក់ពីគុណវុឌ្ឍិសវនកម្មរបស់គាត់ផងដែរ ។

លោក ហួ ណាំគា បានចូលបម្រើការនៅ ហ្វឹស ហ្វាយនែន ជាប្រធានផ្នែក សវនកម្មផ្ទៃក្នុង នៅខែមិថុនា ឆ្នាំ 2018 ។





## ការិយាល័យកណ្តាល

អគារលេខ 15-17 ផ្លូវ 271 សង្កាត់
ទំនប់ទឹក ខណ្ឌចំការមន រាជធានី ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
( ក្បែរផ្សារទំនើប សុវណ្ណា )

093 666 635
www.firstfinance.biz
firstfinance